ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៣ លេខ ៣៦ ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ១៩៩៥

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្ដាហ៍

ក

មាតិកា

I - ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០៥-១០-១៩៩៥ ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ១៨៤២

II - ទីស្តីការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

០៥-១០-១៩៩៥ អនុក្រឹត្យលេខ ៧២ អនក្រ.បក ស្តីពីការកែសំរួលនាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និង ជលសាស្ត្រ អោយទៅជាអគ្គនាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និង ជលសាស្ត្រ ១៨៤៦

០៥-១០-១៩៩៥ អនុក្រឹត្យលេខ ៧៣ អនក្រ.បក ស្តីពីការបង្កើតតំបន់ឧស្សាហកម្មស្ទឹងហាវ ក្រុងព្រះសីហនុ ១៨៤៩

០៥-១០-១៩៩៥ អនុក្រឹត្យលេខ ៧៤ អនក្រ ស្តីពីការបែងចែកឥណទានតាមជំពូកនៃច្បាប់ស្តីពីការកែតំរូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ១៨៥២

០៥-១០-១៩៩៥ អនុក្រឹត្យលេខ ៧៥ អនក្រ.បក ស្តីពីការរំសាយ និងការបង្កើតទីស្នាក់ការត្រួតពិនិត្យច្រកព្រំដែន និងផ្លូវគមនាគមន៍នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ១៨៦៧

០៦-១០-១៩៩៥ អនុក្រឹត្យលេខ ១១១ អនក្រ ស្តីពីការពន្យារពេលចូលនិវត្តន៍មន្ត្រីរាជការ ១៨៨០

២ - សេចក្តីសំរេច

០៣-១០-១៩៩៥ សេចក្តីសំរេចលេខ ៦៨ សសរ ស្តីពីការប្រគល់ភារកិច្ចបណ្តោះអាសន្ន ១៨៨១

០៤-១០-១៩៩៥ សេចក្តីសំរេចលេខ ៦៩ សសរ ស្តីពីដំណោះស្រាយលើសំណូមពរនៃបុគ្គលិក កម្មកររបស់ក្រុមហ៊ុនគង់រថយន្តកម្ពុជា ១៨៨២

III - ការងារបណ្តាក្រសួង

១ - ទីស្តីការរដ្ឋមន្ត្រី ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

០២-១០-៩៥ ប្រកាសលេខ ៣២៩ សហវ.ប្រក.គរ ណែនាំ និង កំណត់ការអនុវត្តន៍ច្បាប់ ស្តីពីអាករពិសេសលើទំនិញមួយចំនួនចំពោះនាំចូលទំនិញ ១៨៨៤

០២-១០-១៩៩៥ ប្រកាសលេខ ៣៣០ សហវ.ប្រក.គរ ស្តីពីការកំណត់អត្រាពន្ធនាំចេញ ចំពោះកៅស៊ូក្រែប និង LATEX ១៨៨៧

០៣-១០-១៩៩៥ ប្រកាសលេខ ៣៣១ ប្រក.សហវ.ពដ ស្តីពីការកំណត់ការអនុវត្តន៍អាករពិសេសលើទំនិញមួយចំនួន អាករលើផលរបរតាមអត្រា ៤ %. និងទោសទណ្ឌសារពើពន្ធ ១៨៨៩

០៣-១០-១៩៩៥ ប្រកាសលេខ ៣៣២ ប្រក.សហវ.ពដ ស្តីពីការកាន់បញ្ជីចំណូល - ចំណាយ ដោយអ្នកជាប់ពន្ធតាមរបបម៉ៅការ ១៨៩១

២ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

ប្រកាស

០៥-១០-១៩៩៥ ប្រកាសលេខ ៩១៥ ពណ.បល.ប្រក ស្តីពីការបង្កើតគណៈកម្មការពិព័រណ៍ជាតិ ១៨៩៤

៣ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

០៥-១០-១៩៩៥ ប្រកាសលេខ ៧៥៤ នប.ប្រក ស្តីពីការបង្កើតការិយាល័យបរិដ្ឋានឧស្សាហកម្ម ១៨៩៧
១០-១០-១៩៩៥ ប្រកាសលេខ ៧៦៣ ផក.ប្រក អនុញ្ញាតអោយលោក ខា ផល្លា ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង២៤សេះ ១៨៩៨
១០-១០-១៩៩៥ ប្រកាសលេខ ៧៦៤ ផក.ប្រក អនុញ្ញាតអោយលោក គី សុខុម ជនជាតិខ្មែរ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៤០សេះ ១៨៩៩
១០-១០-១៩៩៥ ប្រកាសលេខ ៧៦៥ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ប្អូយ វុន ជនជាតិខ្មែរ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង១៦ សេះ ១៨៩៩
១០-១០-១៩៩៥ ប្រកាសលេខ ៧៦៦ ផក.ប្រក អនុញ្ញាតអោយលោក ទូច ខ្នា ជនជាតិខ្មែរ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង១៨ សេះ ១៩០០
១០-១០-១៩៩៥ ប្រកាសលេខ ៧៦៧ ផក.ប្រក អនុញ្ញាតអោយលោក វេង លាងអេង ជនជាតិខ្មែរ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១៥ សេះ ១៩០១
១០-១០-១៩៩៥ ប្រកាសលេខ ៧៦៨ ផក.ប្រក អនុញ្ញាតអោយលោក ញឹម សារី ជនជាតិខ្មែរ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង៤០ សេះ ១៩០១
១០-១០-១៩៩៥ ប្រកាសលេខ ៧៦៩ ផក.ប្រក អនុញ្ញាតអោយលោក សេង ម៉េងទ្រី ជនជាតិខ្មែរ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៤០ សេះ ១៩០២

១០-១០-១៩៩៥	ប្រកាសលេខ ៧៧០ ផក.ប្រក អនុញ្ញាតអោយលោក ចុង ខាវ ជនជាតិខ្មែរ ប្តូរទីតាំងរោងម៉ាស៊ីនផលិតទឹកកកដើម	១៩០៣
១១-១០-១៩៩៥	ប្រកាសលេខ ៧៧៥ ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុនសុរាគារក្បាលពោធិ «ថៃផេងអ៊ា» ពង្រីកផលិតផលចំនួន ២ មុខទៀត	១៩០៣
១៣-១០-១៩៩៥	ប្រកាសលេខ ៧៧៩ ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន «សុរាគារកំពង់ត្រាំ» បន្តដំណើរការផលិតកម្ម នៅក្នុងទីតាំងភូមិកំណាប់ ឃុំរលាំងគ្រើល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ	១៩០៤

៤ - ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

០២-១០-១៩៩៥	ប្រកាសលេខ ២៤៨/៩៥ ពម.ប្រក អនុញ្ញាតអោយកាសែត «សង្គ្រោះខ្មែរ» ផ្ទេរចាងហ្វាងការផ្សាយពីឈ្មោះ ជេតសន ជួន ទៅឈ្មោះ ថាន វុត្ថា វិញ	១៩០៥
០៣-១០-១៩៩៥	ប្រកាសលេខ ២៤៩/៩៥ ពម.ប្រក អនុញ្ញាតអោយកាសែត THE BUSINESS NEWS ចេញផ្សាយជាភាសាអង់គ្លេស	១៩០៦
០៤-១០-១៩៩៥	ប្រកាសលេខ ២៥០/៩៥ ពម.ប្រក អនុញ្ញាតអោយសារពត៌មាន «នគរភ្នំ» ដំណើរការបោះពុម្ពផ្សាយ	១៩០៧
០៥-១០-១៩៩៥	ប្រកាសលេខ ២៥១/៩៥ ពម.ប្រក អនុញ្ញាតអោយកាសែត «យុត្តិធម៌» បោះពុម្ពផ្សាយសាជាថ្មីឡើងវិញ	១៩០៩

៥ - ទីស្តីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

០២-១០-១៩៩៥ ប្រកាសលេខ ១៥៤ បទ.ប្រក ស្តីពីការលុបឈ្មោះមន្ត្រីរាជការបុគ្គលិក ១៩១០
០២-១០-១៩៩៥ ប្រកាសលេខ១៥៥ បទ.ប្រក ស្តីពីការតែងតាំងបដិគ្គាហកៈមន្ទីរប្រៃសនីយ៍ និងទូរគមនាគមន៍ ១៩១២
០២-១០-១៩៩៥ ប្រកាសលេខ ១៥៦ បទ.ប្រក ស្តីពីការបង្កើតក្រុមប្រឹក្សាវិន័យ ១៩១៣
០៥-១០-១៩៩៥ ប្រកាសលេខ ១៥៧ បទ.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ១៩១៤

៦ - រដ្ឋលេខាធិការដ្ឋាន

មុខងារសាធារណៈ

ប្រកាស

០៣-១០-១៩៩៥ ប្រកាសលេខ ១០២០ មស.បល ស្តីពីការតែងតាំងមន្ត្រីរាជការ ១៩១៦

៧ - ទីស្តីការក្រសួងធម្មការ និង

សាសនា

ប្រកាស

០២-១០-១៩៩៥ ប្រកាសលេខ ២០១/៩៥ កធស.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ១៩១៧

៨ - ទីស្តីការរដ្ឋមន្ត្រីក្រសួងគ្រប់គ្រង

បរិដ្ឋាន

ប្រកាស

០២-១០-១៩៩៥ ប្រកាសលេខ ១៨២២ ប្រក.បស្ក ស្តីពីការទទួលស្គាល់ និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការផ្ទេរចូលបំរើការងារនៅក្រសួងគ្រប់គ្រងបរិដ្ឋាន ១៩១៩

ឃ

៩ - ទីស្តីការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

០៦-១០-១៩៩៥	ប្រកាសលេខ ១៦៦ ប្រក.វវស.ប ស្តីពីការ ផ្លាស់ប្តូរកន្លែងធ្វើការរបស់មន្ត្រីរាជការ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានីភ្នំពេញ	១៩២០
០៦-១០-១៩៩៥	ប្រកាសលេខ ១៦៧ ប្រក.វវស.ប ស្តីពីការ លុបឈ្មោះមន្ត្រីរាជការ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តកំពត	១៩២១
០៦-១០-១៩៩៥	ប្រកាសលេខ ១៦៨ ប្រក.វវស.ប ស្តីពីការផ្លាស់ប្តូរកន្លែងធ្វើការ	១៩២៣

I - ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមព្រះរាជក្រឹត្យ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣
- យោងតាមព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- យោងព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពី សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និងអំពីសហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ត្រាស់បង្គាប់

មាត្រា ១ : គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើត និងរៀបរៀងតាមប្រភេទ និងតាមឋានានុក្រម ដូចខាងក្រោមនេះ ÷

ក - ប្រភេទមាតុប្រទេស :

១ - មេដាយជាតូបការៈ

២ - មេដាយព្រះរាជាណាចក្រកម្ពុជា មាន ៥ ថ្នាក់ : មហាសេរីវឌ្ឍន៍ មហាសេនា - ធិបឌិន្ទ - សេនា - អស្សឫទ្ធិ

៣ - មេដាយឯករាជជាតិ

គ្រឿងឥស្សរិយយសប្រភេទនេះ សំរាប់បំពាក់ជូនវរជនដែលមានគុណូបការៈដ៏ឧត្តុង្គឧត្តម ក្នុងការបំរើមាតុប្រទេស ដើម្បីបុព្វហេតុឯករាជ្យ សាមគ្គីភាព ប្រជាធិបតេយ្យ និង សន្តិភាពជាតិ តាមរយៈព្រះរាជក្រឹត្យក្រោយពីការសំរេចរបស់គណៈរដ្ឋមន្ត្រី ហើយត្រូវប្រទានដោយព្រះមហាក្សត្រ ឬ ដោយព្រះរាជតំណាង ។

ខ - ប្រភេទព្រះរាជបល្ល័ង្ក

១ - មេដាយរាជសម្បត្តិ

២ - មេដាយ រដ្ឋកាល មាន ៣ ថ្នាក់ : មាស , ប្រាក់ , សំរិទ្ធ

៣ - មេដាយអនុស្សរា

គ្រឿងឥស្សរិយយសប្រភេទនេះ សំរាប់បំពាក់ជូនវរជនដែលមានគុណបំណាច់ចំពោះព្រះរាជបល្ល័ង្ក ចំពោះព្រះមហាក្សត្រផ្ទាល់ ចំពោះព្រះរាជវង្សានុវង្ស ព្រះមហាក្សត្រ ឬ ជាអនុស្សាវរីយ៍របស់ព្រះមហាក្សត្រ ។

ការផ្តល់ និង បំពាក់គ្រឿងឥស្សរិយយសទាំងនេះ ត្រូវសំរេចដោយព្រះរាជតំរិះផ្ទាល់របស់ព្រះមហាក្សត្រ តាមរយៈក្រឹត្យបរមរាជរាំង ។

គ - ប្រភេទការពារជាតិ :

១ - មេដាយសេនាជ័យសិទ្ធ

២ - មេដាយការពារជាតិ មាន ៣ ថ្នាក់ មាស ប្រាក់ សំរិទ្ធ

គ្រឿងឥស្សរិយយសទាំងនេះ សំរាប់បំពាក់ជូនដល់ពលទាហាន នាយទាហាន នៃ កងកម្លាំងប្រដាប់អាវុធ ឬ នគរបាលដែលមានស្នាដៃឆ្នើមពិសេសក្នុងសង្គ្រាម ឬកិច្ចការពារព្រំដែន និងការពារសន្តិសុខជូនជាតិមាតុភូមិ តាមរយៈព្រះរាជក្រឹត្យ ក្រោយពីការសំរេចរបស់គណៈរដ្ឋមន្ត្រី ហើយត្រូវប្រទានដោយព្រះមហាក្សត្រ ឬ ព្រះរាជតំណាង ។

ឃ - ប្រភេទចំរុះ

១- មេដាយសហមេត្រី មាន ៣ ថ្នាក់ : មាស ប្រាក់ សំរិទ្ធ សំរាប់បំពាក់ជូនអគ្គទូត ឬតំណាងប្រទេសជាមិត្តដែលបានបំពេញការងារ ដើម្បីជាប្រយោជន៍ដល់ចំណងមិត្តភាពប្រទេសទាំងពីរ ។

២- មេដាយសុវត្ថារា មាន ៣ ថ្នាក់ : ធិបឌិន្ទ សេនា អស្សប្ញទ្ធិ សំរាប់បំពាក់ជូនបុគ្គលដែលមានស្នាដៃ និងគុណបំណាច់ខ្ពស់ក្នុងវិស័យ កសិកម្ម និងសេដ្ឋកិច្ច ។

៣- មេដាយមុនីសារាភ័ណ្ឌ មាន៣ ថ្នាក់ : ធិបឌិន្ទ សេនា អស្សប្ញទ្ធិ សំរាប់បំពាក់ជូនបុគ្គលដែលមានស្នាដៃ និង គុណបំណាច់ខ្ពស់ ក្នុងវិស័យសិក្សាធិការ អក្សរសាស្ត្រ វិទ្យាសាស្ត្រ វិចិត្រសិល្បៈ សង្គមកិច្ច ឬ វិស័យផ្សេង ៗ ទៀត ។

៤- មេដាយការងារមាន ៣ ថ្នាក់ : មាស ប្រាក់ សំរិទ្ធ សំរាប់បំពាក់ជូនបុគ្គលដែលមានថ្វីដៃក្នុងការងារផ្នែករដ្ឋបាល ឬ ក្នុងវិស័យឯកជន ។

៥- មេដាយស្ថាបនាជាតិមាន ៣ ថ្នាក់ : មាស ប្រាក់ សំរិទ្ធ សំរាប់បំពាក់ជូនសប្បុរសជន ដែលបានបរិច្ចាគទ្រព្យសម្បត្តិផ្ទាល់ខ្លួនជួយកសាងជាតិ ឬស្ថាបនា សមិទ្ធជាប្រយោជន៍សាធារណៈ ។

– មេដាយខេមរាកីឡាឫទ្ធិ មាន ៣ ថ្នាក់ : មាស ប្រាក់ សំរិទ្ធ សំរាប់បំពាក់ជូនកីឡាករដែលមានស្នាដៃឆ្នើមក្នុងវិស័យកីឡាជាតិ ឬអន្តរជាតិដែលបាននាំមកនូវកិត្តិយសដល់ប្រទេសជាតិ ។

– មេដាយស្ត្រីវឌ្ឍនា មាន ៣ ថ្នាក់ : មាស ប្រាក់ សំរិទ្ធ សំរាប់បំពាក់ជូនស្ត្រី ឬ បុរសដែលមានគុណូបការៈខ្ពង់ខ្ពស់ក្នុងការលើកកំណើងបុព្វហេតុស្ត្រី ។

– គ្រឿងឥស្សរិយយសប្រភេទចំរុះនេះ ត្រូវរៀបចំតាមរយៈអនុក្រឹត្យ និងបំពាក់ដោយនាយករដ្ឋមន្ត្រី ឬ តំណាង ។

មាត្រា ២ : រូបភាពលក្ខណៈសញ្ញាផ្សេង ៗ នៃ ឥស្សរិយយស និង ប្រកាសនីយប័ត្រគ្រឿង ឥស្សរិយយសទាំងនេះត្រូវយកតាមគំរូដែលបានកំណត់ក្នុងព្រះរាជក្រឹត្យ ចុះ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៦៣ ។

មាត្រា ៣ : រៀងរាល់ដំណាច់ឆ្នាំ អាជ្ញាធរមានសមត្ថកិច្ចតាមក្រសួង ឬ តាមអង្គភាពនីមួយៗ មានភារកិច្ចស្រង់បញ្ជីឈ្មោះវរជនដែលត្រូវស្នើរដ្ឋាភិបាល ដើម្បីសំរេចជូនមេដាយ ដោយមានបញ្ជាក់ផងដែរ នូវទង្វើករណ៍ចំពោះករណីផ្ទាល់វរៈជនម្នាក់ ៗ ។ ក្នុងករណីពិសេសបន្ទាន់ និង ចាំបាច់នាយករដ្ឋមន្ត្រី អាចនឹងស្នើរៀបចំពីធីបំពាក់ឥស្សរិយយសនេះជាមុន រួចរៀបចំសំណុំបែបបទស្នើសុំជាខាងក្រោយ ។

មាត្រា ៤ : គ្រឿងឥស្សរិយយស ពុំអាចផ្តល់ជូនឥស្សរជនមួយរូបលើសពីមួយដងក្នុងមួយឆ្នាំបានឡើយ ។ តែមេដាយការពារជាតិ ឬ មេដាយស្ថាបនាជាតិមិនត្រូវគិតបញ្ចូលទេ ។

មាត្រា ៥ : រាជរដ្ឋាភិបាលត្រូវផលិតមេដាយ និង ត្រូវមានសារាចរលំអិតបន្ថែមទៀត ដើម្បីណែនាំដល់អាជ្ញាធរមានសមត្ថកិច្ចគ្រប់ថ្នាក់ អំពីបែបបទ នៃការរៀបចំសំណើសុំគ្រឿងឥស្សរិយយស ។

មាត្រា ៦ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៧ : នាយករដ្ឋមន្ត្រី ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៨ : ព្រះរាជក្រឹត្យនេះមានអានុភាពគតិយុត្តទូទាំងព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅភ្នំពេញ , ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥

ក្នុងព្រះបរមនាម និង តាមព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា	**ហត្ថលេខា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

បានបង្គំទូលថ្វាយ និង ជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី ១ និងទី ២

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ហត្ថលេខា

សុខ អាន **វ៉េង សិរីវុឌ្ឍ**

* * *

II - ទីស្តីការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

រាជធានីភ្នំពេញ ,ថ្ងៃទី [illegible]០ ខែ កញ្ញា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៧២ អនក្រ.[illegible]

ស្តីពីការកែសម្រួលនាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និងជលសាស្ត្រ ឱ្យទៅជាអគ្គនាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និង ជលសាស្ត្រ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើតាមព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សំរេច

មាត្រា ១ : ត្រូវបានកែសំរួលពីនាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និងជលសាស្ត្រ ឱ្យទៅជាអគ្គនាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និងជលសាស្ត្រ មានទីតាំងនៅ រាជធានីភ្នំពេញ និង ស្ថិតនៅក្រោមការគ្រប់គ្រង និង ដឹកនាំផ្ទាល់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

មាត្រា ២ : អគ្គនាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និងជលសាស្ត្រ មានភារកិច្ចសំខាន់ ៗ ដូចខាងក្រោម ÷

- រៀបចំគោលនយោបាយ គោលការណ៍ និងលិខិតបទដ្ឋាន ដែលពាក់ព័ន្ធដល់ធនធានទឹក ទាំងលើដី ទាំងក្រោមដី ដើម្បីធ្វើអាជីវកម្មក្នុងការប្រើប្រាស់ទឹក បំរើអោយដល់ការដាំដុះ និងជីវភាពប្រជារាស្ត្រដោយប្រសិទ្ធភាពខ្ពស់ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស ។
- សិក្សាស្រាវជ្រាវ វាយតម្លៃកំណត់ នូវទិសដៅកម្មវិធីស្តារ និងអភិវឌ្ឍន៍វិស័យធារាសាស្ត្រឧតុនិយម និងជលសាស្ត្រ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស។

- ទទួលខុសត្រូវក្នុងការអនុវត្តន៍សាងសង់ តម្លើង និងជួសជុល នូវប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធឧតុនិយម និង ជលសាស្ត្រ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស ។
- ចាត់តាំងព្យាករណ៍ ឧតុនិយម និងជលសាស្ត្រ រយៈពេលវែង ខ្លី សំដៅបំរើឱ្យគ្រប់វិស័យ និងជូនដំណឹងជាមុននូវគ្រោះធម្មជាតិដែលអាចកើតមានឡើង ដើម្បីមានវិធានការអន្តរាគមន៍ទាន់ពេលវេលា ។
- ប្រមូលចងក្រងឯកសារ និង ធ្វើអាជីវកម្ម នូវទិន្នន័យ ឧតុនិយម និងជលសាស្ត្រ បំរើឱ្យវិស័យនានាដែលមានការពាក់ព័ន្ធជាលក្ខណៈជាតិ និងអន្តរជាតិ ។
- ស្រាវជ្រាវ បច្ចេកទេសវិទ្យាសាស្ត្រ ដើម្បីឱ្យមានវិធានការកែលំអ ផ្សព្វផ្សាយ និងបណ្តុះបណ្តាល ។
- ពង្រឹង និងពង្រីកកិច្ចសហការជាតិ និង ការងារសហប្រតិបត្តិការអន្តរជាតិលើវិស័យធារាសាស្ត្រ ឧតុនិយម និងជលសាស្ត្រ ។

មាត្រា ៣ : រចនាសម្ព័ន្ធចាត់តាំងរបស់អគ្គនាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និង ជលសាស្ត្រ មាន ÷

១- នាយកដ្ឋានរដ្ឋបាល-ផែនការ-ហិរញ្ញវត្ថុ
២- នាយកដ្ឋានស្រាវជ្រាវ និង ផ្សព្វផ្សាយ
៣- នាយកដ្ឋានគ្រប់គ្រងទឹក
៤- នាយកដ្ឋានវិស្វកម្ម
៥- នាយកដ្ឋានជលសាស្ត្រ
៦- នាយកដ្ឋានឧតុនិយម

មាត្រា ៤ : អគ្គនាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និងជលសាស្ត្រ ដឹកនាំដោយអគ្គនាយកមួយរូប និង អគ្គនាយករងមួយចំនួន ជាជំនួយការ ។

មាត្រា ៥ : ក្របខ័ណ្ឌរបស់អគ្គនាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និង ជលសាស្ត្រ អាស្រ័យដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ កំណត់សំរេច ។

មាត្រា ៦ : បទបញ្ញត្តិទាំងឡាយណាដែលមានពីមុន ហើយផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៧ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ស្ថាប័នមានការពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង ៗ ខ្លួន ។

មាត្រា ៨ : អនុក្រឹត្យនេះ មានអនុភាពគតិយុត្តចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

នរោត្តម រណប្ញទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៧៣ អនក្រ-បក
ស្តីពីការបង្កើតតំបន់ឧស្សាហកម្មស្ពានហាវ ក្រុងព្រះសីហនុ

រាជរដ្ឋាភិបាលកម្ពុជា

– បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញ ព្រះរាជក្រឹត្យរបស់ ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស.រកត ១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើតាមព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល .

សម្រេច

មាត្រា ១ : បង្កើតតំបន់ឧស្សាហកម្មមួយនៅក្នុងខ័ណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុមានឈ្មោះថា « តំបន់ឧស្សាហកម្មស្ទឹងហាវ ក្រុងព្រះសីហនុ » ។

មាត្រា ២ : តំបន់ឧស្សាហកម្មស្ទឹងហាវ ក្រុងព្រះសីហនុ ជាតំបន់អភិវឌ្ឍន៍ឧស្សាហកម្មពិសេសមួយដែលប្រមូលផ្តុំសកម្មភាពឧស្សាហកម្មទូទៅ ឧស្សាហកម្មនាំចេញ ឧស្សាហកម្មសេរី និង សេវាកម្មដទៃទៀត ដែលបំរើឱ្យកិច្ចការផលិតកម្មអាជីវកម្ម នៃតំបន់នេះ ។

មាត្រា ៣ : តំបន់ឧស្សាហកម្មស្ទឹងហាវ ក្រុងព្រះសីហនុ មាន ÷

- តំបន់ឧស្សាហកម្ម ទូទៅជាមណ្ឌល នៃសកម្មភាពឧស្សាហកម្ម និងសកម្មភាពដទៃទៀតដែលពាក់ព័ន្ធ នឹងការផលិតទំនិញសំរាប់សេចក្តីត្រូវការក្នុងប្រទេស ឬ និងសំរាប់ការនាំចេញ ។
- តំបន់ឧស្សាហកម្មនាំចេញ ជាមណ្ឌលនៃសកម្មភាពឧស្សាហកម្ម និងសកម្មភាពដទៃទៀតដែលពាក់ព័ន្ធ និងការផលិតទំនិញសំរាប់ការនាំចេញ ចាប់ពី ៨០ % ឡើងទៅ ។

– តំបន់ឧស្សាហកម្ម - សេវាកម្ម គឺជាមណ្ឌលរួចពន្ធ នៃសកម្មភាពផ្គត់ផ្គង់ ស្តុកដាក់តាំង វេចខ្ចប់ផ្គុំផ្សំសំអាត បង្កើយការ នូវផលិតផល សំភារ បរិក្ខារ និងសំភារៈដ៏ទៃទៀតដែលមិនមានការហាមឃាត់ ដោយច្បាប់ សំរាប់បំរើឱ្យសកម្មភាពឧស្សាហកម្ម ។

មាត្រា ៤ : តំបន់ឧស្សាហកម្មស្ទឹងហាវ ក្រុងព្រះសីហនុមានទំហំប្រមាណ១.១៥០ ហិកតា មានទីតាំងដូចបានបញ្ជាក់តាមផែនទី ដែលមានភ្ជាប់នឹងអនុក្រឹត្យនេះ និង ដែលស្ថិតនៅក្នុងចន្លោះ ។

ចាប់ពី

ខ្សែរយៈទទឹង ១០° ៤៣,២ ខ្សែរយៈបណ្តោយ ១០៣° ៣២,៨

និងខ្សែរយៈទទឹង ១០° ៤២,៣ ខ្សែរយៈបណ្តោយ ១០៣° ៣២,៩

ទៅដល់

ខ្សែរយៈទទឹង ១០° ៤៤,១ ខ្សែរយៈបណ្តោយ ១០៣° ៣៧,២

និងខ្សែរយៈទទឹង ១០° ៤៣,២ ខ្សែរយៈបណ្តោយ ១០៣° ៣៧,៥

អាងទឹកសាបដែលមានសញ្ញាបញ្ជាក់ក្នុងផែនទី ជាប្រភពទឹកសាបសំរាប់បំពេញ សេចក្តីត្រូវការរបស់តំបន់ឧស្សាហកម្ម ស្ទឹងហាវ ក្រុងព្រះសីហនុ ។

មាត្រា ៥ : ផ្ទៃដីទាំងអស់ដែលនៅក្នុងបរិវេណតំបន់ឧស្សាហកម្មស្ទឹងហាវ ក្រុងព្រះសីហនុ ដូចបានកំណត់ក្នុងមាត្រា ៤ ជាកម្មសិទ្ធិរបស់រដ្ឋ ហើយត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមប្រឹក្សាភិបាលមួយ ដែលមានសមាសភាព និងដំណើរការ ត្រូវកំណត់ឡើងដោយអនុក្រឹត្យ ។

មាត្រា ៦ : ដើម្បីដំណើរការចាត់ចែងតំបន់ឧស្សាហកម្ម ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានភារកិច្ចរៀបចំធ្វើសំណើបង្កើតអាជ្ញាធរតំបន់ឧស្សាហកម្មជា ដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ ដែលមានសមាសភាពជាតំណា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

••••••

ផែនទី

តំបន់ឧស្សាហកម្ម ស្ទឹងហាវ - ក្រុងព្រះសីហនុ

តំបន់ឧស្សាហកម្មទូទៅ = ១១៥០ ហិកតា



កំណត់សំគាល់

(ទ) អាងទឹកសាប

- - — ខណ្ឌសីមានៃតំបន់ឧស្សាហកម្មទូទៅ

—— ផ្លូវរថភ្លើង

0 ៥០០ ១០០០ ១៥០០ ម៉ែ

ក្រសួង ស្ថាប័ននានាដែលពាក់ព័ន្ធ ។ ការរៀបចំ និងការប្រព្រឹត្តិទៅរបស់អាជ្ញាធរតំបន់ឧស្សាហកម្មកម្ពុជា នឹងត្រូវកំណត់ឡើងដោយអនុក្រឹត្យ ។

មាត្រា ៧ : បទបញ្ញត្តិផ្ទុយទាំងឡាយណាដែលមានឋានានុក្រមស្មើ ឬ ទាបជាងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៨ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល រដ្ឋមន្ត្រី រដ្ឋលេខាធិការដ្ឋាន នៃស្ថាប័នពាក់ព័ន្ធ និង អភិបាលក្រុងព្រះសីហនុ មានភារកិច្ចអនុវត្តអោយបានសំរេចនូវអនុក្រឹត្យនេះតាមសមត្ថកិច្ចរៀង ៗ ខ្លួន ។

មាត្រា ៩ : អនុក្រឹត្យនេះចាប់ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៧៤ អនក្រ
ស្តីពីការបែងចែកឥណទានតាមជំពូក នៃច្បាប់ ស្តីពីការកែតំរូវនៃច្បាប់ ហិរញ្ញវត្ថុសំរាប់ ការគ្រប់គ្រងឆ្នាំ ១៩៩៥
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញ ច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ ០១ នស ៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីអំពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែល ប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ ១១ នស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែល ប្រកាសអោយប្រើដោយព្រះរាជក្រម ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១ : ឥណទានសំរាប់ចំណាយជាប្រចាំ និងជាមូលធនរបស់រដ្ឋ ដែលបានកំណត់ ដោយច្បាប់ ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ត្រូវបានបែងចែកតាមជំពូក ដោយអនុលោមតាមតារាងដែលភ្ជាប់ និង អនុក្រឹត្យនេះ ។

មាត្រា ២ : ការបែងចែកឥណទាននៃជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

មាត្រា ៣ . សមាជិករដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការដ្ឋាន អភិបាលគ្រប់ខេត្ត–ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃ ឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

ការគ្រប់គ្រង ឆ្នាំ ១៩៩៥ — ច្បាប់ថវិកាកែតម្រូវ
ការបែងចែកចំណាយជាប្រចាំ និង ជាមូលធន

ឯកតាគិតជាលានរៀល

លេខជំពូក	ការរាយមុខ	
	១ — ព្រះបរមរាជវាំង	
10	បៀវត្ស និង ប្រាក់បំណាច់	6.160
11	ចំណាយដំណើរការរដ្ឋបាលសំភារៈនិងការផ្គត់ផ្គង់តូច	2.130
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	3.510
50	ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	1.800
	សរុបរួម ១	13.600
	២ — សភាជាតិ	
10	បៀវត្ស និង ប្រាក់បំណាច់	6.410
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់តូច	2.780
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	140
32	អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ	100
50	ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	370
	សរុបរួម ២	9.800
	៣ — ទីស្តីការគណៈរដ្ឋមន្ត្រី	

	ផ្នែក ១ — គណៈរដ្ឋមន្ត្រី	
10	បៀវត្ស និង ប្រាក់បំណាច់	1.075
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	17.115
30	អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច	4.155
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	1.210
50	ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	2.295
	សរុប ផ្នែក ១	25.850
	ផ្នែក ៤ — ទំនាក់ទំនងជាមួយសភា	
10	បៀវត្ស និង ប្រាក់បំណាច់	100
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	500
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	10
50	ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	30
	សរុប ផ្នែក ៤	640
	ផ្នែក ៦ — មុខងារសាធារណៈ	
10	បៀវត្ស និង ប្រាក់បំណាច់	70
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	265
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	5
50	ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	40
	សរុប ផ្នែក ៦	380
	ផ្នែក ៧ — អាកាសចរណ៍ស៊ីវិល	
10	បៀវត្ស និង ប្រាក់បំណាច់	430
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	2.260
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	10
32	អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ	140
50	ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	300
	សរុប ផ្នែក ៧	3.140
	សរុបរួម ៣	30.010
	៤ — ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ	

10	បៀវត្ស និង ប្រាក់បំណាច់	4.650
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការផ្គូសផ្គុលតូច	17.055
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	580
32	អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ	665
50	ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	200
	សរុបរួម ៤	23.150
	៥ — ក្រសួងការពារជាតិ	
10	បៀវត្ស និង ប្រាក់បំណាច់	195.550
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការផ្គូសផ្គុលតូច	106.350
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	6.600
	សរុបរួម ៥	308.500
	៦ — ក្រសួងមហាផ្ទៃ	
	ផ្នែក ១ — សន្តិសុខសាធារណៈ	
10	បៀវត្ស និង ប្រាក់បំណាច់	38.400
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការផ្គូសផ្គុលតូច	64.915
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	1.055
	សរុប ផ្នែក ១	104.370
	ផ្នែក ២ — រដ្ឋបាលទូទៅ	
10	បៀវត្ស និង ប្រាក់បំណាច់	165
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការផ្គូសផ្គុលតូច	3.220
12	ប្រាក់ឧបត្ថម្ភសំរាប់ដំណើរការ អង្គការសាធារណៈរដ្ឋបាល	1.480
30	អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច	1.000
31	អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ	165
50	ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	2.340
51		19.200
	សរុប ផ្នែក ២	27.570
	ផ្នែក ៩ - ខេត្តនានា	
10	បៀវត្ស និង ប្រាក់បំណាច់	6.035
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការផ្គូសផ្គុលតូច	3.070
12	ប្រាក់ឧបត្ថម្ភសំរាប់ដំណើរការ អង្គការសាធារណៈរដ្ឋបាល	12.950

31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	240
	សរុប ផ្នែក ៩	22.295
	សរុបរួម ៦	154.235
	៧ — ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	
	ផ្នែក ១ — ក្រសួង	
10	បៀវត្ស និង ប្រាក់បំណាច់	2.125
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	4.125
12	ប្រាក់ឧបត្ថម្ភសំរាប់ដំណើរការ អង្គការសាធារណៈរដ្ឋបាល	2.420
20	ការប្រាក់នៃខ្ចីបុលរយៈពេលវែង មធ្យម និង ខ្លី	19.700
30	អន្តរាគមន៍វិស័យសេដ្ឋកិច្ច	6.100
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	50
50	ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	7.275
51	ការវិនិយោគដោយហិរញ្ញប្បទានពីបរទេសផ្ទាល់	40.000
53	ការទូទាត់បំណុល	52.300
	សរុប ផ្នែក ១	134.095
	ផ្នែក ៩ — ខេត្តនានា	
10	បៀវត្ស និង ប្រាក់បំណាច់	670
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	525
12	ប្រាក់ឧបត្ថម្ភសំរាប់ដំណើរការ អង្គការសាធារណៈរដ្ឋបាល	115
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	125
50	ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	485
	សរុប ផ្នែក ៩	1.920
	សរុបរួម ៧	136.015
	៨ — ក្រសួងឃោសនាការ	
	ផ្នែក ១ — ក្រសួង	
10	បៀវត្ស និង ប្រាក់បំណាច់	730
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	2.760

31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	55
32	អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ	5
50	ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	2.600
	សរុបផ្នែក ១	6.150
	ផ្នែក ២ — ខេត្តនានា	
10	បៀវត្ស និង ប្រាក់បំណាច់	710
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	630
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	55
50	ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	240
	សរុប ផ្នែក ២	1.635
	សរុបជំពូក ៨	7.785
	៩ — ក្រសួងសាធារណៈការដឹកជញ្ជូន	
	ផ្នែក ១ — សាធារណៈការ	
10	បៀវត្ស និង ប្រាក់បំណាច់	1.315
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	605
30	អន្តរាគមន៍វិស័យសេដ្ឋកិច្ច	5.145
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	65
50	ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	21.655
51	ការវិនិយោគដោយហិរញ្ញប្បទានពីបរទេសផ្ទាល់	97.500
	សរុប ផ្នែក ១	126.285
	ផ្នែក ២ — ខេត្តនានា	
10	បៀវត្ស និង ប្រាក់បំណាច់	2.920
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	1.180
30	អន្តរាគមន៍វិស័យសេដ្ឋកិច្ច	15
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	95
50	ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	3.275
	សរុប ផ្នែក ២	7.485
	សរុបជំពូក ៩	133.770
	១០ — ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ	
	ផ្នែក ១ — ក្រសួង	

10	បៀវត្ស និង ប្រាក់បំណាច់	2.595
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	4.065
30	អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច	900
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	195
32	អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ	50
50	ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	9.455
51	ការវិនិយោគដោយ ហិរញ្ញប្បទានពីបរទេសផ្ទាល់	48.500
	សរុប ផ្នែក ១	65.760
	ផ្នែក ៩ — ខេត្តនានា	
10	បៀវត្ស និង ប្រាក់បំណាច់	3.570
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	1.660
30	អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច	1.045
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	115
	សរុប ផ្នែក ៩	6.390
	សរុបរួម ១០	72.150
	១១ — ក្រសួងយុត្តិធម៌	
	ផ្នែក ១ — ក្រសួង	
10	បៀវត្ស និង ប្រាក់បំណាច់	375
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	1.090
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	25
50	ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	310
	សរុប ផ្នែក ១	1.800
	ផ្នែក ២ — តុលាការ	
10	បៀវត្ស និង ប្រាក់បំណាច់	90
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	335
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	15
50	ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	30
	សរុប ផ្នែក ២	470
	ផ្នែក ៣ — សាលាឧទ្ធរណ៍	
10	បៀវត្ស និង ប្រាក់បំណាច់	40

11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	115
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	5
50	ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	30
	សរុប ជំពូក ២	190
	ជំពូក ៩ — ខេត្តនានា	
10	បៀវត្ស និង ប្រាក់បំណាច់	410
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	520
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	45
	សរុប ជំពូក ៩	975
	សរុបរួម ១១	3.435
	ជំពូក ១២ — ក្រសួងអប់រំយុវជននិងកីឡា	
	ជំពូក ១ — អប់រំ	
10	បៀវត្ស និង ប្រាក់បំណាច់	1.020
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	9.925
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	180
50	ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	1.840
51	ការវិនិយោគដោយ ហិរញ្ញប្បទានពីបរទេសផ្ទាល់	42.100
	សរុប ជំពូក ១	55.065
	ជំពូក ២ — ឧត្តមសិក្សា	
10	បៀវត្ស និង ប្រាក់បំណាច់	1.090
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	805
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	305
32	អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ	20
50	ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	1.200
	សរុប ជំពូក ២	3.420
	ជំពូក ៣ — យុវជននិងកីឡា	
10	បៀវត្ស និង ប្រាក់បំណាច់	360
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	885
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	280
32	អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ	20

50	ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	220
	សរុប ផ្នែក ៣	1.765
	ផ្នែក ៩ — ខេត្តនានា	
10	បៀវត្ស និង ប្រាក់បំណាច់	60.750
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	2.320
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	1.100
	សរុប ផ្នែក ៩	64.170
	សរុបរួម ១២	124.420
	១៣ — ក្រសួងពាណិជ្ជកម្ម	
	ផ្នែក ១ — ក្រសួង	
10	បៀវត្ស និង ប្រាក់បំណាច់	495
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	995
30	អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច	1.030
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	20
50	ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	550
	សរុប ផ្នែក ១	3.090
	ផ្នែក ៩ — ខេត្តនានា	
10	បៀវត្ស និង ប្រាក់បំណាច់	690
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	675
30	អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច	90
	សរុប ផ្នែក ៩	1.455
	សរុបរួម ១២	4.545
	ផ្នែក ១៤ — ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល	
	ផ្នែក ១ — ក្រសួង	
10	បៀវត្ស និង ប្រាក់បំណាច់	470
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	340
30	អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច	6.385
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	25
50	ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	3.300

51	ការវិនិយោគដោយ ហិរញ្ញប្បទានពីបរទេសផ្ទាល់	54.200
	សរុប ផ្នែក ១	64.720
	ផ្នែក ២ — ខេត្តនានា	
10	បៀវត្ស និង ប្រាក់បំណាច់	910
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	405
30	អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច	1.185
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	50
	សរុប ផ្នែក ២	2.550
	សរុបរួម ១៤	67.270
	១៥ — ក្រសួងផែនការ	
	ផ្នែក ១ — ក្រសួង	
10	បៀវត្ស និង ប្រាក់បំណាច់	250
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	430
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	10
50	ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	110
	សរុប ផ្នែក ១	800
	ផ្នែក ២ — ខេត្តនានា	
10	បៀវត្ស និង ប្រាក់បំណាច់	635
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	310
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	20
	សរុប ផ្នែក ២	965
	សរុបរួម ១៥	1.765
	១៦ — ក្រសួងសុខាភិបាល	
	ផ្នែក ១ — ក្រសួង	
10	បៀវត្ស និង ប្រាក់បំណាច់	2.490
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	15.550
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	180
32	អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ	640
50	ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	4.150
51	ការវិនិយោគដោយ ហិរញ្ញប្បទានពីបរទេសផ្ទាល់	21.400

	សរុប ជំពូក ១	44.410
	ជំពូក ៩ — ខេត្តនានា	
10	បៀវត្ស និង ប្រាក់បំណាច់	7.780
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់តូច	9.865
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	75
	សរុប ជំពូក ៩	17.720
	សរុបរួម ១៦	62.130
	១៧ — ក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម	
	ជំពូក ១ — ក្រសួង	
10	បៀវត្ស និង ប្រាក់បំណាច់	175
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់តូច	780
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	10
32	អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ	85
50	ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	375
	សរុប ជំពូក ១	1.425
	ជំពូក ៩ — ខេត្តនានា	
10	បៀវត្ស និង ប្រាក់បំណាច់	225
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់តូច	130
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	10
	សរុប ជំពូក ៩	365
	សរុបរួម ១៧	1.790
	១៨ — ក្រសួងធម្មការ និងកិច្ចការសាសនា	
	ជំពូក ១ — ក្រសួង	
10	បៀវត្ស និង ប្រាក់បំណាច់	155
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់តូច	315
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	10
50	ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	30
	សរុប ជំពូក ១	510
	ជំពូក ៩ — ខេត្តនានា	
10	បៀវត្ស និង ប្រាក់បំណាច់	330

11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	175
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	35
	សរុប ផ្នែក ៩	540
	សរុបរួម ១៨	1.050
	១៩ — ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍	
	ផ្នែក ១ — ក្រសួង	
10	បៀវត្ស និង ប្រាក់បំណាច់	1.100
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	22.670
30	អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច	10
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	25
32	អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ	50
50	ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	550
	សរុប ផ្នែក ១	24.405
	ផ្នែក ៩ — ខេត្តនានា	
10	បៀវត្ស និង ប្រាក់បំណាច់	425
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	330
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	20
	សរុប ផ្នែក ៩	775
	សរុបរួម ១៩	25.180

	២០ — ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ	
	ផ្នែក ១ — ក្រសួង	
10	បៀវត្ស និង ប្រាក់បំណាច់	1.025
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	1.955
30	អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច	5
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	100
50	ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	295
	សរុប ផ្នែក ១	3.380
	ផ្នែក ៩ — ខេត្តនានា	

10	បៀវត្ស និង ប្រាក់បំណាច់	1.150
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	400
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	30
	សរុប ផ្នែក ៩	1.580
	សរុបរួម ២០	4.960
	២១ — ក្រសួងសង្គមកិច្ចការងារនិងអតីតយុទ្ធជន	
	ផ្នែក ១ — ក្រសួង	
10	បៀវត្ស និង ប្រាក់បំណាច់	325
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	725
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	255
32	អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ	125
50	ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	350
	សរុប ផ្នែក ១	1.780
	ផ្នែក ៩ — ខេត្តនានា	
10	បៀវត្ស និង ប្រាក់បំណាច់	860
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	830
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	34.265
	សរុប ផ្នែក ៩	35.955
	សរុបរួម ២១	37.735

	២២ — ក្រសួងបរិស្ថាន	
	ផ្នែក ១ — ក្រសួង	
10	បៀវត្ស និង ប្រាក់បំណាច់	230
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	1.115
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	5
50	ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	470
	សរុប ផ្នែក ១	1.820
	ផ្នែក ៩ — ខេត្តនានា	
10	បៀវត្ស និង ប្រាក់បំណាច់	200

11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	440
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	35
	សរុប ផ្នែក ៩	675
	សរុបរួម ១៦	2.495
	២៣ — ក្រសួងអភិវឌ្ឍន៍ជនបទ	
	ផ្នែក ១ — ក្រសួង	
10	បៀវត្ស និង ប្រាក់បំណាច់	1.085
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	1.890
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	95
50	ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	60
51	ការវិនិយោគដោយ ហិរញ្ញប្បទានពីបរទេសផ្ទាល់	49 200
	សរុបរួម ២៣	52.330
	២៤ — រដ្ឋលេខាធិការដ្ឋានកិច្ចការនារី	
	ផ្នែក ១ — ក្រសួង	
10	បៀវត្ស និង ប្រាក់បំណាច់	100
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	350
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	100
50	ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	170
	សរុប ផ្នែក ១	720
	ផ្នែក ៩ — ខេត្តនានា	
10	បៀវត្ស និង ប្រាក់បំណាច់	100
11	ចំណាយដំណើរ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	245
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	15
	សរុប ផ្នែក ៩	360
	សរុបរួម ២៣	1.080
	៩៩ — ចំណាយផ្សេងៗនិងពុំបានគ្រោងទុក	
41	ចំណាយមិនបានគ្រោងទុក	3.800
	សរុបរួម ៩៩	3.800
	សរុបរួម ចំណាយ	1.283.000

រាជធានីភ្នំពេញ ,ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៧៥ អនក្រ.បក

ស្តីពី

ការរំសាយ និង ការបង្កើតទីស្នាក់ការត្រួតពិនិត្យ

តាមច្រកព្រំដែន និងផ្លូវគមនាគមន៍នៅទូទាំង

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤–៩៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ រស.រកត.១០៩៤.៩០ ចុះថ្ងៃទី ៣១ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រង ការប្រើប្រាស់អាវុធ និង ជាតិផ្ទុះគ្រប់ប្រភេទ
- យោងតាមលទ្ធផល នៃកិច្ចប្រជុំអន្តរក្រសួងនាថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ១៩៩៥ ពិភាក្សាលើបញ្ហា រំសាយ និងការបង្កើតទីស្នាក់ការត្រួតពិនិត្យនៅតាមច្រកព្រំដែន និងផ្លូវគមនាគមន៍នៅទូទាំងព្រះ រាជាណាចក្រកម្ពុជា
- យោងតាមសភាពការណ៍ចាំបាច់

សម្រេច

មាត្រា ១ : ត្រូវបានរំសាយទីស្នាក់ការត្រួតពិនិត្យដែលបានបង្កើតកន្លងមកទាំងអស់ស្ថិតនៅតាមច្រកព្រំដែន និង ផ្លូវគមនាគមន៍នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២ : ត្រូវបានបង្កើតឡើងវិញនូវទីស្នាក់ការត្រួតពិនិត្យ តាមច្រកចេញ-ចូលនៅព្រំដែន និងនៅតាមផ្លូវគមនាគមន៍ ជាអាទិ ផ្លូវគោក ផ្លូវទឹក ផ្លូវដែក ផ្លូវសមុទ្រ ផ្លូវអាកាសនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ស្ថិតក្រោមការគ្រប់គ្រង របស់ថ្នាក់កណ្តាលមានដូចខាងក្រោម ÷

ក- អំពីផ្លូវជាតិ :

១-ផ្លូវជាតិលេខ ១ ពីព្រំដែនបាវិត មកដល់រាជធានីភ្នំពេញមាន ០២ ចំណុច ÷ បាវិត (ខេត្តស្វាយរៀង) និង អ្នកលឿងត្រើយខាងលិច (ខេត្តកណ្តាល) ។

២-ផ្លូវជាតិលេខ ២ ពីព្រំដែនភ្នំដិនមកដល់ រាជធានីភ្នំពេញមាន ០២ ចំណុច ÷ ភ្នំដិន (ខេត្តតាកែវ) និងកំពង់ទួល (ខេត្តកណ្តាល) ។

៣-ផ្លូវជាតិលេខ ៣ ពីទីរួមខេត្តកំពតមកដល់ រាជធានីភ្នំពេញ ០២ ចំណុច÷ កំពង់បាយ (ខេត្តកំពត) និងព្រះធាតុ(ខេត្តកណ្តាល) ។

៤-ផ្លូវជាតិលេខ ៤ ពីក្រុងព្រះសីហនុមកដល់ រាជធានីភ្នំពេញមាន ០២ ចំណុច ÷ កំពង់ផែក្រុងព្រះសីហនុ និង ក្រែងត្រយឹង (ខេត្តកំពង់ស្ពឺ) ។

៥-ផ្លូវជាតិលេខ ៥ ពីព្រំដែនប៉ោយប៉ែតមកដល់ រាជធានីភ្នំពេញមាន ០៤ ចំណុច ÷ ប៉ោយប៉ែត ទឹកថ្លា (ខេត្តបន្ទាយមានជ័យ) អណ្តូងចេញ (ខេត្តបាត់ដំបង) និងផ្សារដែកលើ (ផ្លូវបំបែកនៃផ្លូវជាតិលេខ ៥ និងលេខ ២៦ ស្រុកឧត្តុង ខេត្តកំពង់ស្ពឺ)

៦-ផ្លូវជាតិលេខ ៦ ពីខេត្តកំពង់ធំមកដល់រាជធានីភ្នំពេញមាន ០១ ចំណុច ÷ ថ្នល់កែង (ស្រុកបាធាយ ខេត្តកំពង់ចាម) ។

ខ-អំពីផ្លូវទឹក :

១–តាមដងទន្លេមេគង្គលើពីព្រំដែនប្រទេសឡាវ មកដល់រាជធានីភ្នំពេញមាន ១ ចំណុច ÷ អូរស្វាយ – កោះឈើទាលធំ (ខេត្តស្ទឹងត្រែង) ។

២–តាមដងទន្លេសាបពីខេត្តសៀមរាបមកដល់រាជធានីភ្នំពេញមាន ០១ ចំណុច ÷ ព្រែកក្ដាម (ខេត្តកណ្ដាល) ។

៣–តាមដងទន្លេមេគង្គក្រោម ពីព្រំដែនប្រទេសវៀតណាមមកដល់រាជធានីភ្នំពេញមាន ០៣ ចំណុច ÷ កោះរការ (ខេត្តព្រៃវែង) ក្ដមសំណរ (ខេត្តកណ្ដាល) និងកោះគេជា (ខេត្តកណ្ដាល) ។

៤–តាមដងទន្លេបាសាក់ពីព្រំដែនប្រទេសវៀតណាមមកដល់រាជធានីភ្នំពេញមាន ០៣ ចំណុច ÷ ខ្នាតាំងយូ–ព្រៃធំ និង ដើមមៀន (ខេត្តកណ្ដាល) ។

៥–នៅរាជធានីភ្នំពេញមាន កំពង់ផែអន្តរជាតិទីក្រុងភ្នំពេញ និង កំពង់ផែនាវាក្នុងប្រទេស ។

គ– អំពីផ្លូវដែក :

– ផ្លូវដែកទាំងពីរទិសមាន ០៦ ចំណុច ÷ស្ថានីយ៍រាជាយស្ម័យានកម្ពុជា (ភ្នំពេញ) ស្ថានីយ៍រថភ្លើងតាំងក្រសាំង ស្ថានីយ៍រថភ្លើងក្រុងព្រះសីហនុ ស្ថានីយ៍រថភ្លើងទ្បីមខេត្តពោធិសាត់ ស្ថានីយ៍រថភ្លើង ទ្បីម ខេត្តបាត់ដំបង និងស្ថានីយ៍រថភ្លើងទ្បីមខេត្តបន្ទាយមានជ័យ ។

ឃ– អំពីផ្លូវសមុទ្រ :

១–ខេត្តកោះកុងមាន ០៥ ចំណុច ÷ កោះស្ដេច ប៉ាក់ខ្លង ថ្មស នាងកុក និង ស្រែអំបិល ។

២–ក្រុងព្រះសីហនុមាន ០៣ ចំណុច ÷ កំពង់ផែពាណិជ្ជកម្មអន្តរជាតិក្រុងព្រះសីហនុ ទំនប់ រលក និង ស្ទឹងហាវ ។

៣-ខេត្តកំពតមាន ០៤ ចំណុច ÷ ទាន់ហាន់ កោះសេះ ត្រពាំងល្ពៅ និងផែទីរួមខេត្តកំពត ។

៤-ទីក្រុងកែបមាន ០១ ចំណុច ÷ ផែទីក្រុងកែប ។

គ- អំពីផ្លូវអាកាស :

- ផ្លូវអាកាសមាន៨ ចំណុច ÷ ព្រលានយន្តហោះអន្តរជាតិពោធិចិន្តុង ព្រលានយន្តហោះកងកេង ក្រុងព្រះសីហនុ ខេត្តសៀមរាប ទីរួមខេត្តកោះកុង វាលបែកចានទីរួមខេត្តបាត់ដំបង ទីរួមខេត្តស្ទឹងត្រែង បានលុងទីរួមខេត្តរតនៈគីរី និង ព្រលានយន្តហោះទីរួមខេត្ត មណ្ឌលគីរី ។

មាត្រា ៣ : ត្រូវបានកំណត់ និងបង្កើតទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិ និង ច្រកចេញ-ចូលព្រំ ដែនប្រទេសមានដូចខាងក្រោម ÷

១- ច្រកទ្វារព្រំដែនអន្តរជាតិ

- **រាជធានីភ្នំពេញ :**

១-ព្រលានយន្តហោះអន្តរជាតិពោធិចិនតុង

២-កំពង់ផែពាណិជ្ជកម្មអន្តរជាតិរាជធានីភ្នំពេញ

- ក្រុងព្រះសីហនុ :

៣-កំពង់ផែពាណិជ្ជកម្មអន្តរជាតិក្រុងព្រះសីហនុ

- ខេត្តស្វាយរៀង :

៤-បាវិត (លើផ្លូវជាតិលេខ ១)

- ខេត្ត កណ្តាល - ព្រៃវែង

៥-ក្អមសំណរ - កោះរការ (ទន្លេមេគង្គ)

- ខេត្តតាកែវ

៦-ភ្នំដិន (លើផ្លូវជាតិលេខ ២)

២- ច្រកទ្វារព្រំដែនចេញចូលប្រទេសទ្វេភាគី

- ខេត្តរតនៈគីរី :

១–អូរយ៉ាដាវ (លើផ្លូវជាតិលេខ ១៩)

– ខេត្ត មណ្ឌលគិរី :

២–ដាក់ដាម (លើផ្លូវជាតិលេខ ១៤)

– ខេត្ត ក្រចេះ :

៣–ស្នួល (លើផ្លូវជាតិលេខ ១៣)

– ខេត្ត កំពង់ចាម :

៤–ត្រពាំងផ្លុង (លើផ្លូវជាតិលេខ ៧)

– ខេត្ត កំពត :

៥–ព្រែកចាក (លើផ្លូវជាតិលេខ ១៧)

៣–ច្រកទ្វារព្រំដែនចេញ–ចូលតំបន់ព្រំដែន :

– ខេត្ត មណ្ឌលគិរី :

១–ឋាឡាខេ (ផ្លូវគោក)

– ខេត្ត ក្រចេះ

២–ជ័យឃ្លាំង

៣–វ៉ាលី

– ខេត្ត កំពង់ចាម :

៤–មេមត់ (ផ្លូវគោក)

៥–ដា (ផ្លូវគោក)

៦–ជាំក្រវៀន (ផ្លូវគោក)

– ខេត្ត ព្រៃវែង :

៧–ពាមបន្ទា (ផ្លូវទឹក)

៨–កោះសំពៅ (ផ្លូវទឹក)

– ខេត្ត ស្វាយរៀង :

៩–បុសមន (ផ្លូវគោក)

១០–ព្រៃវល្លិ (ផ្លូវគោក)

១១-សំរោង (ផ្លូវគោក)

- ខេត្ត កណ្ដាល :

១២-ជ្រៃធំ-ខ្នាតាំងយូ (ផ្លូវទឹក)

- ខេត្ត តាកែវ :

១៣-ចាក់ដៃ (ផ្លូវគោក)

១៤-កំពង់ក្រសាំង (ផ្លូវទឹក)

- ខេត្ត កំពត :

១៥-ទាន់ហាន់ (ផ្លូវសមុទ្រ)

១៦-កោះសេះ (ផ្លូវសមុទ្រ)

១៧-ត្រពាំងល្ពៅ (ផ្លូវសមុទ្រ)

១៨-ទីរួមខេត្ត (ផែ)

- ទីក្រុងកែប

១៩-ផែទីក្រុងកែប

- ក្រុងព្រះសីហនុ :

២០-ទំនប់រលក (ផែ)

២១-ស្ទឹងហាវ

- ខេត្ត កោះកុង :

២២-កោះស្ដេច (ផែ)

២៣-ចាំក់ខ្វង (ផែ)

២៤-នាងកុក (ផ្លូវគោក)

២៥-ថ្មស

២៦-ស្រែអំបិល

- ខេត្ត ពោធិសាត់ :

២៧-ភ្នំប្ញស្សី

- ខេត្ត បន្ទាយមានជ័យ :

២៨–ប៉ោយប៉ែត (ផ្លូវគោក)

២៩–បឹងត្រកួន

– ខេត្ត សៀមរាប – ឧត្តរមានជ័យ :

៣០–អូរស្មាច់ (ផ្លូវគោក)

– ខេត្ត ព្រះវិហារ :

៣១–អានសេះ

– ខេត្ត ស្ទឹងត្រែង :

៣២–អូរស្វាយ–កោះឈើទាលធំ (ផ្លូវទឹក)

៣៣–ដុងក្រឡ (ផ្លូវគោក)

មាត្រា ៤ : ត្រូវបានបង្កើតទីស្នាក់ការត្រួតពិនិត្យអាវុធ ជាតិផ្ទុះ នៅលើផ្លូវជាតិ តាមច្រកចេញ–ចូលរាជធានីភ្នំពេញ

១–ផ្លូវជាតិលេខ ១ (ចំណុចសង្កាត់និរោធ ខ័ណ្ឌមានជ័យ)

២–ផ្លូវជាតិលេខ ៣ (ចំណុចសង្កាត់ពងទឹក ខ័ណ្ឌដង្កោ)

៣–ផ្លូវជាតិលេខ ៤ (ចំណុចសង្កាត់ចោមចៅ ខ័ណ្ឌដង្កោ)

៤–ផ្លូវជាតិលេខ ៥ (ចំណុចសង្កាត់ស្វាយប៉ាក ខ័ណ្ឌឫស្សីកែវ)

៥–ផ្លូវជាតិលេខ ៦ A (ចំណុចសង្កាត់ព្រែកលាប ខ័ណ្ឌឫស្សីកែវ)

មាត្រា ៥ : ទីតាំងនៃទីស្នាក់ការត្រួតពិនិត្យ នៅផ្ទៃក្នុងប្រទេសទាំងអស់ ត្រូវរៀបចំអោយស្ថិតនៅឆ្ងាយពីទី ប្រជុំជន សាលារៀន និង វត្តអារាម ដើម្បីធានាសុវត្ថិភាពជូនប្រជារាស្ត្រ និង សិស្សានុសិស្ស ។

មាត្រា ៦ : សមាសភាព តួនាទី និងភារកិច្ចរបស់កងកម្លាំងប្រដាប់អាវុធ និងភ្នាក់ងារមានសមត្ថកិច្ចប្រចាំការ នៅតាមទីស្នាក់ការត្រួតពិនិត្យ មានដូចខាងក្រោម ÷

ក– អំពីសមាសភាព :

ក-១–នៅតាមច្រកទ្វារព្រំដែនអន្តរជាតិ :

១–កំលាំងនគរបាលជាតិ ជាប្រធាន

២–ភ្នាក់ងារគាំកុងត្រូល សមាជិក

៣-ភ្នាក់ងារគយ និងរដ្ឋាករ សមាជិក

៤-ភ្នាក់ងារកសិកម្ម (ភូត្តគាមអនាម័យ ជលផល រុក្ខាប្រមាញ់ ផលិតកម្មបសុព្យាបាល សមាជិក

៥-ភ្នាក់ងារបក្ខាឡឹសក្តិ សមាជិក

៦-ភ្នាក់ងារ ត្រួតពិនិត្យឱសថ សមាជិក

- ដោយឡែកនៅតាម ÷

+ ព្រលានយន្តហោះអន្តរជាតិ មានអាជ្ញាធរអាកាសចរស៊ីវិល ជាប្រធាន និង គ្មានភ្នាក់ងាររុក្ខា ប្រមាញ់ទេ ។

+ កំពង់ផែពាណិជ្ជកម្មអន្តរជាតិ មានប្រធានមណ្ឌលអាជីវកម្ម កំពង់ផែអន្តរជាតិ ជាប្រធាន និងមានកាំសាបជាសមាជិកថែមទៀត ។

+ ទីស្នាក់ការត្រួតពិនិត្យចរិត គ្មានភ្នាក់ងាររុក្ខាប្រមាញ់ទេ ។

ក-២- នៅតាមទីស្នាក់ការត្រួតពិនិត្យ នៃច្រកចេញ-ចូល ព្រំដែន កម្ពុជាឡាវ និងកម្ពុជា -វៀតណាម

១-កំលាំងនគរបាលជាតិ (ផ្នែកអន្តោប្រវេសន៍) ជាប្រធាន

២-កំលាំងកងរាជអាវុធហត្ថជាតិ សមាជិក

៣-ភ្នាក់ងារកាំកុងត្រូល សមាជិក

៤-ភ្នាក់ងារគយ និងរដ្ឋាករ សមាជិក

៥-ភ្នាក់ងារកសិកម្ម (ភូត្តគាមអនាម័យ ផលិតកម្មបសុព្យាបាល រុក្ខាប្រមាញ់ ឬកៅស៊ូជលផល សមាជិក

៦-ភ្នាក់ងារបក្ខាឡឹសក្តិ សមាជិក

៧-ភ្នាក់ងារ ត្រួតពិនិត្យឱសថ សមាជិក

ក-៣- នៅតាមទីស្នាក់ការត្រួតពិនិត្យ តាមផ្លូវគោក និងផ្លូវទឹកផ្ទៃក្នុងប្រទេសៈ

១-កំលាំងនគរបាលជាតិ ជាប្រធាន

២-កំលាំងកងរាជអាវុធហត្ថជាតិ សមាជិក

៣-ភ្នាក់ងារកាំកុងត្រូល សមាជិក

៤–ភ្នាក់ងារគយ និងរដ្ឋាករ សមាជិក

៥–ភ្នាក់ងារកសិកម្ម សមាជិក

ក-៤–នៅតាមព្រលានយន្តហោះផ្ទៃក្នុងប្រទេស ÷

១–អាជ្ញាធរអាកាសចរស៊ីវិល ជាប្រធាន

២–កំលាំងនគរបាលជាតិ សមាជិក

៣–កំលាំងកងរាជអាវុធហត្ថជាតិ សមាជិក

៤–ភ្នាក់ងារកាំកុងត្រូល សមាជិក

៥–ភ្នាក់ងារគយ និងរដ្ឋាករ សមាជិក

ក-៥–នៅតាមទីស្នាក់ការត្រួតពិនិត្យច្រកចេញ–ចូលព្រំដែនកម្ពុជា–ថៃ ÷

១–កំលាំងកងរាជអាវុធហត្ថជាតិ ជាប្រធាន

២–កំលាំងនគរបាលជាតិ (ផ្នែកអន្តោប្រវេសន៍) សមាជិក

៣–ភ្នាក់ងារគយ និងរដ្ឋាករ សមាជិក

៤–ភ្នាក់ងារកាំកុងត្រូល សមាជិក

៥–ភ្នាក់ងារកសិកម្ម សមាជិក

ក-៦–នៅតាមទីស្នាក់ការត្រួតពិនិត្យអាវុធជាតិផ្ទះ :

១–កំលាំងកងរាជអាវុធហត្ថជាតិ ជាប្រធាន

២–កំលាំងនគរបាលជាតិ សមាជិក

ខ–អំពីតួនាទីភារកិច្ចនៃទីស្នាក់ការត្រួតពិនិត្យ និងកំលាំងត្រួតពិនិត្យនៅតាមទីស្នាក់ការ ត្រួតពិនិត្យនីមួយៗ :

ខ-១–ទីស្នាក់ការត្រួតពិនិត្យនីមួយៗ ត្រូវធានាអោយបានល្អ ÷

+ កិច្ចថែរក្សាការពារអធិបតេយ្យភាព បូរណភាពទឹកដី និងការអនុវត្តច្បាប់នៃព្រះរាជាណាចក្រកម្ពុជា (សំរាប់ច្រកទ្វារព្រំដែន) ។

+ កិច្ចការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សង្គម

+ គ្រប់គ្រងសេដ្ឋកិច្ច

+ សំរួលចរាចរការដឹកជញ្ជូនការធ្វើដំណើរទៅមករបស់ប្រជាពលរដ្ឋកម្ពុជា និងជនបរទេស

+ រកអោយឃើញ ទប់ស្កាត់ និងបង្ក្រាបទាន់ពេលរាល់បទល្មើសច្បាប់នានា (ពិសេសបទល្មើស ព្រំដែន) ។

+ ដោយឡែកទីស្នាក់ការត្រួតពិនិត្យអាវុធ ជាតិផ្ទុះ ទទួលបន្ទុកក្នុងការត្រួតពិនិត្យមនុស្សនិងអាវុធ ជាតិផ្ទុះខុសច្បាប ជាពិសេសគឺត្រួតពិត្យតែនៅពេលចូលក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ ។

ខ-២–តួនាទី ភារកិច្ចនិងសិទ្ធិអំណាចរបស់គងកំលាំងប្រដាប់អាវុធ និង ភ្នាក់ងារជំនាញមានសមត្ថកិច្ចដែលប្រចាំការនៅទីស្នាក់ការត្រួតពិនិត្យ ត្រូវអនុវត្តតាមច្បាប់ លិខិតបទដ្ឋានរបស់រាជរដ្ឋាភិបាល និងប្រកាសរបស់ក្រសួងស្ថាប័នសាមី មានជាអាទិដូចខាងក្រោម ÷

១–កំលាំងយោធា និងកំលាំងកងរាជអាវុធហត្ថជាតិ ទទួលបន្ទុកការគ្រប់គ្រងក្នុងកិច្ចការពារសន្តិសុខ ទប់ស្កាត់រាល់ការរំលោភ និងបទល្មើសប្រដាប់អាវុធផ្នែកយោធា ដែកឆេះអាវុធ ជាតិផ្ទុះ ប៉ុន្តែមិនត្រូតត្រាបញ្ហាលើកិច្ចការជំនាញខាងរដ្ឋបាល និងសេដ្ឋកិច្ចទេ ។

២–កំលាំងនគរបាលជាតិទទួលបន្ទុកគ្រប់គ្រង និងត្រួតពិនិត្យការចេញចូលឆ្លងកាត់ព្រំដែនត្រួតពិនិត្យការងារចរាចរ ការធ្វើដំណើរទៅមករបស់ជនបរទេស និងជនស៊ីវិលជាប្រជាពលរដ្ឋកម្ពុជា បង្ក្រាបបានទាន់ពេលវេលាបទល្មើសឆ្លងដែន និងបទល្មើសផ្សេងៗ រួមជាមួយកំលាំងមានសមត្ថកិច្ច ដែកឆេះអាវុធជាតិផ្ទុះ សំដៅរក្សាសន្តិសុខ និង សុវត្ថិភាព សណ្តាប់ធ្នាប់សង្គម ។

៣–ភ្នាក់ងារកាំកុងត្រូលទទួលបន្ទុកក្នុងការត្រួតពិនិត្យលើបរិមាណ ទម្ងន់ គុណភាពសភាពផលិតផល នៃទំនិញនាំចេញ–ចូល ព្រមទាំងចេញវិញ្ញាបនប័ត្រលើបរិមាណទម្ងន គុណភាព និង សភាព

ផលិតផល នៃទំនិញជូនម្ចាស់ទំនិញដើម្បីធ្វើជាមូលដ្ឋានអោយភ្នាក់ងារគយ និងរដ្ឋាករ ក្នុងការប្រមូលពន្ធ ។

- សោហ៊ុយដែលម្ចាស់ទំនិញត្រូវបង់អោយភ្នាក់ងារកាំកុងត្រូលក្នុងការចេញវិញ្ញាបនប័ត្រនេះ ត្រូវកំណត់ដោយប្រកាសរួមរវាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ។

៤-ភ្នាក់ងារគយ និងរដ្ឋាករសហការជាមួយភ្នាក់ងារជំនាញ នៃក្រសួងស្ថាប័នដែលឈរប្រចាំការនៅទីស្នាក់ការត្រួតពិនិត្យ ទទួលបន្ទុកក្នុងការត្រួតពិនិត្យ លើមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទទំនិញ ឥវ៉ាន់អ្នកដំណើរ កញ្ចប់ ឬហិបផ្ញើតាមប្រៃសណីយ៍ រូបិយវត្ថុ លោហធាតុត្បូងថ្ម មានតំលៃ ថ្នាំពុល អាវុធ ដើម្បីធ្វើការប្រមូលពន្ធនាំចេញនាំចូល និងពន្ធផ្សេង ។ ទៀត ព្រមទាំងទប់ស្កាត់ នឹងបង្ក្រាបអំពើគេចពន្ធ និង អំពើរំលោភកម្មសេដ្ឋកិច្ច ។ ល ។

៥-ភ្នាក់ងារកសិកម្មទទួលបន្ទុកក្នុងការត្រួតពិនិត្យតាមមុខជំនាញរៀងៗខ្លួនជាក់ស្ដែងគឺ ÷

- ភ្នាក់ងាររុក្ខាប្រមាញ់ ត្រួតពិនិត្យការដឹកជញ្ជូនឈើ អនុផលព្រៃឈើ និងផលិតផល មាន ដើមកំណើតចេញពីឈើ ។
- ភ្នាក់ងារជលផលត្រួតពិនិត្យការដឹកជញ្ជូនផលនេសាទនិងផលិតផលចេញពីវិស័យ ជលផល ។
- ភ្នាក់ងារបសុព្យាបាលត្រួតពិនិត្យការដឹកជញ្ជូនសត្វគ្រប់ប្រភេទ និងផលិតផលមានដើម កំណើតពីសត្វ ។
- ភ្នាក់ងារភូត្គតាមអនាម័យត្រួតពិនិត្យផលិតផល និងទំនិញមានដើមកំណើតពីរុក្ខជាតិ ដែលធ្វើការនាំចេញ និងនាំចូល ។

៦-ភ្នាក់ងារត្រួតពិនិត្យឱសថទទួលបន្ទុកត្រួតពិនិត្យបែបបទនាំចូល នាំចេញផលិតផលឱសថ វិញ្ញាបនប័ត្រនាំចូល-នាំចេញផលិតផលឱសថ និងត្រួតពិនិត្យ គុណភាពឱសថ ។

៧-ចត្តាឡីសក្តិទទួលបន្ទុកត្រួតពិនិត្យលើវិញ្ញាបនប័ត្រសុខភាពមនុស្ស និងលក្ខណៈអនាម័យនៃមធ្យោបាយដឹកជញ្ជូនចេញ-ចូល ឆ្លងកាត់ព្រំដែន ។

មាត្រា ៧ : កងកំលាំងប្រដាប់អាវុធ ភ្នាក់ងារ ឬជនណាដែលប្រចាំការនៅទីស្នាក់ការត្រួតពិនិត្យហើយបែរជា ឆ្លៀតប្រើប្រាស់តួនាទីភារកិច្ច និងសិទ្ធិអំណាចរបស់ខ្លួនបង្កអោយមានការលំបាកស្មុគស្មាញដល់ការធ្វើដំណើររបស់ជនបរទេស ភ្ញៀវទេសចរណ៍ ប្រជាពលរដ្ឋ ឬ បង្កអោយមានការយឺតយ៉ាវដោយគ្មានមូលហេតុដល់ការនាំចេញ-នាំចូល ការដឹកជញ្ជូនទំនិញ សំភារៈ វត្ថុធាតុដើម និងផលិតផល ផ្សេងៗរបស់ក្រុមហ៊ុន ឬ ឯកជននិងធ្វើអោយមានការរាំងស្ទះក្នុងការប្រមូលពន្ធត្រូវផ្តន្ទាទោសតាម ច្បាប់ជាធរមាន ។

- កងកំលាំងប្រដាប់អាវុធ និង ភ្នាក់ងារមានសមត្ថកិច្ចដែលប្រចាំការនៅទីស្នាក់ការត្រួតពិនិត្យ ត្រូវបំពេញភារកិច្ចរបស់ខ្លួនអោយមានប្រសិទ្ធភាពខ្ពស់ និង យ៉ាងសកម្មប្រកបដោយអាកប្បកិរិយា សុភាពរាបសារ ជៀសវាងចាននៅការប៉ះទង្គិច ខាងសតិអារម្មណ៍ចំពោះប្រជាលរដ្ឋអ្នកធ្វើដំណើរជាទូទៅដោយគ្មានមូលហេតុសមស្រប ។
- កងកំលាំងប្រដាប់អាវុធ និង ភ្នាក់ងារមានសមត្ថកិច្ចដែលប្រចាំការនៅទីស្នាក់ការត្រួតពិនិត្យ ក្រសួងស្ថាប័នសាមីត្រូវធ្វើការផ្លាស់ប្តូរក្នុងរយៈពេល ០៣ ខែម្តង ជាកំហិតនិងត្រូវធ្វើបញ្ជីរាយនាមកងកំលាំងប្រដាប់អាវុធ និងភ្នាក់ងារមានសមត្ថកិច្ចទាំងនោះ មកអង្គភាពអធិការកិច្ចរាជរដ្ឋាភិបាល រៀងរាល់លើកផ្លាស់ប្តូរម្តង ៗ ។
- ក្រុម ឬជនប្រដាប់អាវុធដែលបង្កើតទីស្នាក់ការត្រួតពិនិត្យដោយខុសច្បាប់ បង្កអោយមានការយឺតយ៉ាវដល់ការធ្វើដំណើរដឹកជញ្ជូនទំនិញ សំភារៈ វត្ថុធាតុដើម ឬបាត់បង់ទ្រព្យសម្បត្តិអាយុជីវិតរបស់ប្រជាពលរដ្ឋកម្ពុជា និងជនបរទេសត្រូវធ្វើការឃាត់ខ្លួន និងបញ្ជូនសំណុំរឿងទៅតុលាការ ដើម្បីផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

មាត្រា ៨ : ត្រូវបានបង្កើតអង្គភាពអធិការកិច្ចរាជរដ្ឋាភិបាលមួយស្ថិតក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់របស់ ឯកឧត្តមទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិការកិច្ច រាជរដ្ឋាភិបាល សំរាប់ធ្វើអធិការកិច្ចលើគ្រប់ទីស្នាក់ការ និងបោសសំអាតទីស្នាក់ការត្រួតពិនិត្យមិនស្របច្បាប់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា និងមានសមាសភាពតំណាងទីស្តីការគណៈរដ្ឋមន្ត្រី
និងតំណាងអធិការកិច្ចក្រសួងស្ថាប័នសាម៉ីជាសមាជិក ។

មាត្រា ៩ : អង្គភាពអធិការកិច្ចរាជរដ្ឋាភិបាលមានក្រុមអធិការកិច្ចចំនួន ០៣ ក្រុម សំរាប់ ជំនួយការគឺ ÷

១–ក្រុមអធិការកិច្ចផ្លូវគោក–ព្រលានយន្តហោះ
២–ក្រុមអធិការកិច្ចផ្លូវទឹក
៣–ក្រុមអធិការកិច្ចផ្លូវសមុទ្រ

– សមាសភាពនៃក្រុមអធិការកិច្ចនិមួយៗរួមមាន ÷

១–មន្ត្រីក្រោមឱវាទផ្ទាល់ឯកឧត្តមទេសរដ្ឋមន្ត្រី	ជាប្រធាន
២–តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៣–តំណាងអធិការកិច្ចរបស់ក្រសួងស្ថាប័នសាម៉ី	សមាជិក

– តួនាទីភារកិច្ច និងសិទ្ធិអំណាចរបស់អង្គភាពអធិការកិច្ចរាជរដ្ឋាភិបាល និងក្រុមអធិការកិច្ចផ្លូវគោក –ព្រលានយន្តហោះ ផ្លូវទឹក និង ផ្លូវសមុទ្រ អាស្រ័យដោយឯកឧត្តមទេសរដ្ឋមន្ត្រី កំណត់សំរេច ។

មាត្រា ១០ : មិនអនុញ្ញាតអោយអាជ្ញាធរខេត្ត–ក្រុងបង្កើតទីស្នាក់ការត្រួតពិនិត្យដោយឡែកផ្សេងទៀតឡើយ ។

មាត្រា ១១ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ១២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃបណ្ដាក្រសួង ស្ថាប័នពាក់ព័ន្ធ ប្រតិភូរាជរដ្ឋាភិបាល ប្រចាំរាជធានីភ្នំពេញ អភិបាលគ្រប់ខេត្ត-ក្រុង និង ឯកឧត្ដមទេសរដ្ឋមន្ត្រី ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពតាំងពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្ថលេខា និង ត្រា ហត្ថលេខា និង ត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ១១០ អនក្រ

ស្ដីពីការពន្យារពេលចូលនិវត្តន៍មន្ត្រីរាជការ រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

- យោងមាត្រា ៦៣ ជំពូកទី ១០ នៃច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០៦ នស.៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤
- តាមសំណើរបស់មន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមយោបល់ឯកភាពរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការមុខងារសាធារណៈ

សម្រេច

មាត្រា ១ : យល់ព្រមពន្យារពេលចូលនិវត្តន៍ចំនួន ០១ ឆ្នាំ ទៅទៀតសំរាប់លោក **ថ្នាក់ ឡេង** ប្រធានមន្ទីរ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយគិតចាប់ពីថ្ងៃទី ១៦ ខែ សីហាឆ្នាំ ១៩៩៥ ដល់ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ១៩៩៦ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន រដ្ឋលេខា ធិការ នៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ព្រមទាំងលោក **ថ្នាក់ ឡេង** ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

២ - សេចក្តីសម្រេច

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ តុលា ឆ្

សេចក្តីសម្រេចលេខ ៦៨ សសរ

ស្តីពីការប្រគល់ភារកិច្ចបណ្តោះអាសន្ន

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- ផ្អែកតាមការចាំបាច់

សំរេច

ប្រការ ១ : ប្រគល់ភារកិច្ចជូនឯកឧត្តម **ជា ចាន់តូ** រដ្ឋមន្ត្រីក្រសួងផែនការ ជារដ្ឋមន្ត្រីស្តីទីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចាប់ពីថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៩៥ រហូតដល់ថ្ងៃឯកឧត្តម **គាត ឈន់** ត្រឡប់មកពីបំពេញ បេសកកម្ម នៅប្រទេសសឹង្ហបូរី វិញ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តម **ជា ចាន់តូ** ត្រូវទទួលអនុវត្តសេចក្តីសំរេច ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខា តទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ៦៩ សសរ

ស្តីពីដំណោះស្រាយលើសំណូមពរ នៃបុគ្គលិក

កម្មកររបស់ក្រុមហ៊ុនកង់រថយន្តកម្ពុជា

* * *

យោង : – សំណូមពររបស់បុគ្គលិក កម្មករ ក្រុមហ៊ុនកង់រថយន្តកម្ពុជា ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៩៥ ។

– របាយការណ៍របស់តំណាងបុគ្គលិក កម្មករ ក្រុមហ៊ុនកង់រថយន្តកម្ពុជា ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ។

– លិខិតលេខ ១៤៩៦ បល.លស ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីសំណើស៊ើបអង្កេតរកការណ៍ និងគោលការណ៍សំរាប់ដោះស្រាយសំណូមពររបស់ បុគ្គលិក កម្មករ ក្រុមហ៊ុនកង់រថយន្តកម្ពុជា ។

– លិខិតលេខ ១៥៦៦ ឧសក.លស ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការសុំ គោលការណ៍ដោះស្រាយសំណូមពររបស់បុគ្គលិក កម្មករ ក្រុមហ៊ុនកង់រថយន្ត កម្ពុជា

សំរេច

ប្រការ ១ : យល់ព្រមអោយចូលនិវត្តន៍ចំពោះបុគ្គលិក កម្មករ ក្រុមហ៊ុនកង់រថយន្តកម្ពុជា ដែលមានអតីតភាពការងារ ចាប់ពី ២០ឆ្នាំឡើង ។ ចំពោះអ្នកមានអតីតភាពការងារក្រោម ២០ឆ្នាំ នឹងត្រូវអនុវត្តតាមច្បាប់ ដែលនឹងមានជាធរមាន។

ប្រការ ២ : យល់ព្រមដោះស្រាយជូនតាមសំណូមពររបស់បុគ្គលិក កម្មករ ក្រុមហ៊ុនកង់រថយន្ត កម្ពុជា នូវទ្រព្យសម្បត្តិរបស់សហជីពមូលដ្ឋាន ។

ប្រការ ៣ : យល់ព្រមដោះស្រាយប្រាក់ចំនួន ០៤ខែ នៃប្រាក់ខែម្នាក់ជូនបុគ្គលិក កម្មករនៃ ក្រុមហ៊ុនកង់រថយន្តកម្ពុជា ក្នុងនោះមានប្រាក់មូលនិធិថ្លៃងសរសើរ ឆ្នាំ ១៩៩៤ ចំនួន ០២ ខែ និង ប្រាក់ឧបត្ថម្ភបន្ថែម ចំនួន ០២ ខែ ។ ចំពោះសំណូមពរប្រាក់ឧបត្ថម្ភចំនួន ១.៥០០ ដុល្លារអាមេរិក សំរាប់ម្នាក់ ៗ នោះ រាជរដ្ឋាភិបាល មិនអាចដោះស្រាយជូនបានឡើយ ព្រោះប្រាក់នេះជាទុនរបស់ ថវិការដ្ឋ ។

ប្រការ ៤ : ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ដើម្បីឈានទៅផ្ទេរការគ្រប់គ្រងរោង ចក្រអោយក្រុមហ៊ុនវិនិយោគទុនអោយបានឆាប់បំផុត ។

ប្រការ ៥ : សេចក្តីសំរេចនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះ ហត្ថលេខាតទៅ ។

សម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១
ព្រះហស្តលេខា និងត្រា
នរោត្តម រណឫទ្ធិ

សម្តេចនាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា និងត្រា
ហ៊ុន សែន

* * *

III - ការងារបណ្តាក្រសួង

១ - ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសណែនាំ និង កំណត់ការអនុវត្តន៍ច្បាប់
លេខ ៣២៩ សហវ. ប្រក.គរ
ស្តីពីអាករពិសេសលើទំនិញមួយចំនួនចំពោះ ទំនិញនាំចូល

* * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីប្រកាសអោយប្រើច្បាប់ ស្តីពីការកែតម្រូវនៃច្បាប់ ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ។

សំរេច

ប្រការ ១ : បណ្តាទំនិញដែលនាំចូលសំរាប់ដាក់អោយប្រើប្រាស់ក្នុងប្រទេសជាតិត្រូវបង់អាករ ពិសេសលើទំនិញមួយចំនួន មានដូចខាងក្រោមនេះ ÷

លេខសំគាល់	ភាយមុខទំនិញ	អត្រាអាករពិសេស
២២០២.	ទឹករួមទាំងទឹកមីណេរ៉ាល់ និង ទឹកអោនជាតិឧស្ម័ន, មាន ដាក់ស្ករ ឬ ក៏សារជាតិផ្អែមផ្សេងទៀត ឬគ្រឿងក្រអូប ហើយភេសជ្ជៈដទៃទៀតដែលគ្មានជាតិស្រា លើកលែងតែទឹកផអផ្លែឈើ ឬ ទឹកផមបន្លែនៅលេខ ២០.០៩ ។	
	–ទឹករួមទាំងទឹកខនិជ និង ទឹកដែលមានជាតិឧស្ម័ន មានដាក់ស្ករ ឬ សារជាតិផ្អែមផ្សេងៗទៀត ឬ គ្រឿង ក្រអូប	
២២០២.១០.១០	–ទឹករួមទាំងទឹកខនិជ (ទឹកមីណេរ៉ាល់)	០%
២២០២.១០.៩០	–ទឹកអោនជាតិឧស្ម័នបន្ថែមស្ករឬសារជាតិផ្អែកផ្សេងៗទៀត ឬគ្រឿងក្រអូប.	១០%

២២០១.៩០.០០	--ផ្សេងទៀត	១០%
២២០៣.០០.០០	ស្រាបៀរម៉ាល់	១០%
២២០៤.០០.០០	ស្រាទំពាំងបាយជូរស្រស់រួមទាំងស្រាទំពាំងបាយជូ ដែលមានជាតិសុរា ទឹកទំពាំងបាយជូសំរាប់ធ្វើសុរាក្រៅពីលេខ ២០.០៩	១០%
២២០៥.០០.០០	ស្រាវ៉ែមុត និង ស្រាទំពាំងបាយជូស្រស់ផ្សេងទៀតផ្សំពីរុក្ខជាតិ និង សារជាតិក្រអូប	១០%
២២០៦.០០.០០	ភេសជ្ជៈធូរផ្សេងទៀត «ដូចជាស៊ីដ្រភេសជ្ជៈធ្វើដោយទឹកផ្លែប៉ោមពារ ភេសជ្ជៈធ្វើដោយទឹកផ្លែព័» អ៊ីដ្រូម៉ែល «ភេសជ្ជៈផ្សំដោយទឹក និង ទឹក ឃ្មុំ» ជាដើម ។	១០%
២២០៧.០០.០០	អាល់កុលអេទីលីកមិនទាន់បំប្លែងធម្មជាតិ ដែលមានកំរិតជាតិសុរាពី ៨០% នៃឯកតាចំណុះ ឬ លើសពីនេះ ។ អាល់កុលអេទីលីក និង ភេសជ្ជមានជាតិសុរា ដែលបាត់បង់កំរិតសុរាដើមរបស់វា ។	
២២.០៨	អាល់កុលអេទីលីតបាត់បង់ធាតុសុទ្ធ ដែលមានកំរិតជាតិសុរាក្នុងឯកតា ចំណុះ ៨០%នៃចំណុះ និងភេសជ្ជៈមានជាតិសុរា ភេសជ្ជៈស្រវឹងផ្សេងៗ ទៀតការរៀបចំកៃច្នៃសុរាផ្សំក្នុងប្រភេទដែលប្រើសំរាប់ផលិតភេសជ្ជៈ ។	១០%
២៤០២.០០.០០	ចារីស៊ីហ្គាររួមទាំងស៊ីហ្គាចុងកាត់ស៊ីហ្គាតូចៗ និងបារីផលិតពីថ្នាំជក់ ឬពី ផលនៃថ្នាំជក់ ។	១០%
២៧១០.០០.២៧	--ប្រេងសាំង Super សំរាប់យានយន្ត	២០%
២៧១០.០០.៣៤	--ប្រេងសាំងធម្មតា សំរាប់យានយន្ត	២០%
២៧១០.០០.៩៩	--ប្រេងរំអិល	២០%

ប្រការ ២ : មូលដ្ឋានកំណត់អាករពិសេសលើទំនិញមួយចំនួនគឺ ជាតំលៃក្នុងគយនៃផលិតផលនាំចូល បូកបន្ថែមពន្ធ និង អាករដែលត្រូវបង់នាពេលនាំចូល លើកលែងតែអាករពិសេសខ្លួនឯងនេះ និង អាករប្រើប្រាស់ដែលត្រូវបង់ ។

ប្រការ ៣ : អាករពិសេសលើទំនិញមួយចំនួន ត្រូវប្រមូលនាឱកាសនាំចូលដោយអង្គភាពគយ និង រដ្ឋាករក្នុងលក្ខខ័ណ្ឌ និង តាមបទបញ្ញត្តិដូចគ្នានឹងពន្ធគយ និង អាករប្រើប្រាស់ ។

ប្រការ ៤ : ចំពោះមុខទំនិញដែលត្រូវបង់អាករពិសេសលើទំនិញមួយចំនួន នៅពេលភ្នាក់ងារគយ និង រដ្ឋាករប្រមូលពន្ធត្រូវសរសេរបង្កាន់ដៃទទួលប្រាក់មួយសន្លឹកចំពោះទំនិញមួយមុខ រួចនៅពេលផ្ទេរប្រាក់ចូលថវិការដ្ឋ ត្រូវសរសេរ

ខ្ទង់ចំណូលតាមនាមវលីថវិកាលេខ ១២.០៨.០១ និងរបបគយដែលត្រូវចុះនៅក្នុងប្រតិវេទន៍គយគឺលេខ ០១០ ។

ប្រការ ៥ : ចំពោះទំនិញដែលបាននាំចូល និងបានធ្វើបែបបទនៃការមកដល់ មុនថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ១៩៩៥ ប៉ុន្តែពុំទាន់បានប្រមូលពន្ធគឺពុំត្រូវបានប្រមូលអាករ ពិសេសលើ ទំនិញមួយចំនួននេះឡើយ ។

ប្រការ ៦ : ប្រការនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ១៩៩៥ នេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខា និង ត្រា
គាត ឈន់

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៣៣០ សហវ.ប្រក.គរ
ស្ដីពីការកំណត់អត្រាពន្ធនាំចេញ
ចំពោះកៅស៊ូក្រែប និង កៅស៊ូ LATEX

* * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្ដីពីការ តែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាល

- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញសេចក្តីជូនដំណឹងលេខ ១៤៦១ សជណ.ពហ ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការកំណត់អត្រាពន្ធនាំចេញចំពោះកៅស៊ូ LATEX និង កៅស៊ូក្រេប,
- បានឃើញសេចក្តីសំរេចលេខ ០០២ សសរ ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការប្រើប្រាស់តារាងពន្ធគយ ។

សំរេច

ប្រការ ១ : អត្រាពន្ធនាំចេញចំពោះកៅស៊ូ LATEX និងកៅស៊ូក្រេប ត្រូវបានកែសំរួល និង កំណត់ ១០% ។

ប្រការ ២ : អត្រាពន្ធនាំចេញចំពោះកៅស៊ូ LATEX និង កៅស៊ូក្រេបដែលផ្តុយពីប្រការ ១ ខាងលើនេះ ត្រូវចាត់ទុកជានិរាករណ៍ ចាប់ពីថ្ងៃប្រកាសផ្សាយអនុវត្តប្រកាសនេះ ។

ប្រការ ៣ : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខា និង ត្រា
គាត ឈន់

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ

ប្រកាសលេខ ៣៣១ ប្រក.សហវ.ពដ
ស្តីពីការកំណត់ការអនុវត្តន៍អាករពិសេស
លើទំនិញមួយចំនួន
អាករលើផលរបរតាមអត្រា ៤ %
និង ទោសទណ្ឌសារពើពន្ធ

* * *

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រម ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការកែតំរូវនៃច្បាប់ ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ។

សំរេច

ប្រការ ១ : ចាប់ពីថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ១៩៩៥ តទៅ :

ក–គ្រប់ប្រតិបត្តិការប្រគល់–ទទួលផលិតផលផលិត ឬ ធ្វើនៅព្រះរាជាណាចក្រកម្ពុជា ដែលស្ថិតក្នុងដែនអនុវត្តន៍នៃអាករពិសេសលើទំនិញមួយ

ចំនួនមិនគិតថាការទូទាត់ប្រាក់ធ្វើនៅថ្ងៃណាឡើយ ត្រូវជាប់អាករពិសេស លើទំនិញមួយចំនួននេះ តាមអត្រា ១០% និង ២០%

ខ–រាល់ប្រតិបត្តិការប្រគល់ ទទួលទំនិញនៃសកម្មភាពខាងពាណិជ្ជកម្ម ព្រៃឈើ និង នេសាទ មិនគិតថា ការទូទាត់ប្រាក់ធ្វើនៅថ្ងៃណាឡើយ ហើយដែលពីមុនជាប់អាករ លើផលរបរតាមអត្រា ២% នោះ ត្រូវជាប់អាករលើផលរបរតាមអត្រា ៤% វិញ ។

ដោយឡែកសំរាប់ប្រតិបត្តិការនៃសកម្មភាពខាងសេវាកម្ម អត្រាអាករលើផលរបរ ៤% ត្រូវអនុវត្តលើការទូទាត់ប្រាក់ ដែលធ្វើឡើងចាប់ពីថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៩៥ តទៅ ។

គ–ត្រូវអនុវត្តការដាក់ទោសទណ្ឌទាក់ទិននឹងមូលដ្ឋានកំណត់ពន្ធ និង ការត្រួតពិនិត្យ ដែលរួមមានការប្រាក់យឺតយ៉ាវដែលមានអត្រា ២% ក្នុងមួយខែ ប្រាក់បន្ថែម ១០% ២៥% និង ៤០% ដូចមានចែងក្នុងមាត្រា ៩, ១២, ១៣ នៃច្បាប់ស្តីពីហិរញ្ញវត្ថុដូច បានយោងខាងលើ ។

ចំពោះរាល់ទោសទណ្ឌដែលបានប្រព្រឹត្តខុសមុនថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៩៥ ហើយដែលអង្គភាពពន្ធដារពុំទាន់បានអនុវត្តនីតិវិធីនៃការកំណត់ពន្ធឡើងវិញ នោះ ត្រូវអនុវត្តការដាក់ទោសតាមបទបញ្ញត្តិដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ នៃចំណុច គ ខាងលើនេះដែរ ។

ប្រការ ២ : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខា និង ត្រា
គាត ឈន់

* * *

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ៣៣២ ប្រក.សហវ.៣៥

ស្តីពីការកាន់បញ្ជីចំណូល-ចំណាយ
ដោយអ្នកជាប់ពន្ធតាមរបបម៉ៅការ

* * *

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច
និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤

សំរេច

ប្រការ ១ : សហគ្រាសជាប់ពន្ធតាមរបបម៉ៅការមានផលរបរ ដូចមានចែងក្នុងមាត្រា ៥៤ នៃច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ មានកាតព្វកិច្ច ÷

ក- ត្រូវកាត់បញ្ជីចំណូលភ្ជាប់ដោយវិក័យប័ត្រ ដើម្បីកំណត់ផលរបររបស់ខ្លួន ។

ខ- សហគ្រាសដែលមានសកម្មភាពលក់ទំនិញក្នុងសភាពដើម ឬផលិតផលដែលផលិត បានត្រូវកាន់បន្ថែមនូវបញ្ជីកត់ត្រាការទិញ ភ្ជាប់ដោយវិក័យប័ត្រ និង សក្ខីប័ត្រនានា ។

ប្រការ ២ : បញ្ជីចំណូល និង បញ្ជីកត់ត្រាការទិញ ដូចបានចែងក្នុងប្រការ ១ ខាងលើមុននឹង ប្រើប្រាស់ ត្រូវតែបានប្រធានសាខាពន្ធដារខេត្ត–ក្រុង ចុះហត្ថលេខាបញ្ជាក់ និង ចុះលេខ គ្រប់ទំព័រជា មុន ។
ត្រូវបញ្ជាក់នៅខាងខ្នងទំព័រនៃក្របបញ្ជីថា :
បញ្ជីនេះសំរាប់លោក លោកស្រី...................................
ប្រើប្រាស់ធ្វើជាបញ្ជី....................និងមានចំនួន.........ទំព័រ......
ដែលបានចុះហត្ថលេខា និងបោះត្រាបញ្ជាក់ពីទំព័រទី ១ ដល់ទំព័រចុងក្រោយរួចហើយ ដោយយើងប្រធានសាខាពន្ធដារខេត្ត ។

ថ្ងៃទី ខែ ឆ្នាំ

ហត្ថលេខា និង ត្រា

ប្រការ ៣ : រាល់ការកត់ត្រានៅក្នុងបញ្ជីចំណូល និង បញ្ជីកត់ត្រាការទិញ ត្រូវមានសក្ខីប័ត្រសំរាប់បញ្ជាក់និង មិនត្រូវទុកអោយមានចន្លោះបន្ទាត់ ឬកោសលុបដោយប្រការណាមួយ ឬសរសេរជ្រៀតបន្ទាត់ឡើយ ។

ក្នុងការកត់ត្រាម្តង ៗ ត្រូវចុះកាលបរិច្ឆេទចុះឈ្មោះទំនិញបានលក់ ឬបានទិញ ឬសេវាដែលបាន ធ្វើហើយ និង ចំនួនប្រាក់ដែលបានទទួល (បានចាយសំរាប់ទិញ) ។

រាល់ប្រតិបត្តិការលក់ ឬ ផ្គត់ផ្គង់សេវា ដែលទទួលបានជាសាច់ប្រាក់ដល់ដៃ ដែលមានតំ លៃក្រោម ១០០.០០០រៀល បានមកពីការលក់រាយ ឬ ផ្គត់ផ្គង់សេវាអោយអតិថិជនជក់ជន អាច អនុញ្ញាតអោយកត់ត្រាចុះក្នុងបញ្ជីចំណូលជាសរុបនៅពេលចុងថ្ងៃនីមួយ ៗ ។

នៅចុងខែនីមួយ ៗ ត្រូវបូកសរុបចំនួនទឹកប្រាក់ដែលបានកត់ត្រានៅក្នុងបញ្ជី ។

ប្រការ ៤ : វិក័យប័ត្រដែលបានបង្កើតឡើង ទោះបីដោយសហគ្រាសជាប់ពន្ធអាករតាមរបបម៉ៅការ ដូចបានចែងក្នុងមាត្រា ៥៤ នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការ

គ្រប់គ្រងឆ្នាំ ១៩៩៥ ឬ ដោយ សហគ្រាសជាប់ ពន្ធអាករតាមរបបពិតក៏ដោយ ត្រូវតែមានចុះលេខរៀងរៀបបន្តគ្នាជាលំ ដាប់ ចាប់ពីថ្ងៃទី ១ រហូតដល់ចុងឆ្នាំ ។ វិក័យប័ត្រមួយលេខៗ ត្រូវមានពីរសន្លឹក មួយសន្លឹកសំរាប់ប្រគល់ជូនអតិថិជន និង មួយសន្លឹកទៀតសំរាប់រក្សាទុកជាសក្ខីប័ត្រ ។ និទ្ទេសដែលចែងក្នុងវិក័យប័ត្រ ត្រូវមានដូចតទៅ ÷

- ឈ្មោះ ឬ នាមករណ៍របស់អ្នកលក់ ឬ អ្នកធ្វើសេវា
- អាស័យដ្ឋាន និង លេខ អត្តសញ្ញាណកម្មសារពើពន្ធរបស់អ្នកលក់ (បើមាន)
- ឈ្មោះ ឬ នាមករណ៍ព្រមទាំងអាស័យដ្ឋានរបស់អ្នកទិញ
- កាលបរិច្ឆេទនៃការលក់ ឬ ការផ្គត់ផ្គង់សេវា
- ឈ្មោះទំនិញដែលបានលក់ ឬ សេវាដែលបានធ្វើ
- បរិមាណដែលបានលក់
- ចំនួនប្រាក់ ដែលបានទទួល

ប្រការ ៥ : បញ្ជី និង សក្ខីប័ត្រត្រូវរក្សាទុកក្នុងរយៈពេល ៣ ឆ្នាំ គិតចាប់ពីថ្ងៃទី ៣១ ខែ ធ្នូ នៃឆ្នាំ ជាប់ពន្ធ ។

ប្រការ ៦ : អ្នកជាប់ពន្ធអាករ មានកាតព្វកិច្ចត្រូវអនុវត្តតាមបទបញ្ញត្តិដូចមានចែងខាងលើនេះ ។ អង្គការពន្ធមានភារកិច្ចធ្វើអោយអ្នកជាប់ពន្ធអាករទាំងឡាយ គោរព និងប្រតិបត្តិតាមបទបញ្ញត្តិទាំងនេះអោយបានត្រឹមត្រូវ ។

ប្រការ ៧ : ប្រកាសនេះ ត្រូវអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ហត្ថលេខា និង ត្រា
គាត ឈន់

* * *

២ - ទីស្តីការរដ្ឋមន្ត្រីក្រសួង ពាណិជ្ជកម្ម

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៤១៥ ពណ.បល.ប្រក.

ប្រកាស

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទព្រះ**នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាព រាជរដ្ឋាភិបាលកម្ពុជា
- ពិនិត្យលើការងារចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការពិព័រណ៍ជាតិ របស់ក្រសួង ដើម្បីរៀបចំចាត់តាំងពិព័រណ៍សមិទ្ធផល ពាណិជ្ជកម្ម ដែលរួមមានសមាសភាពដូចខាងក្រោម ÷

១_ឯកឧត្តម **តុប សំ**	អនុរដ្ឋលេខាធិការ	ជាប្រធាន
២_លោក **គីម ស៊ីថន**	ប្រធាននាយកដ្ឋានបុគ្គលិក	ជាអនុប្រធាន
៣_លោក **កែវ សុខណៃ**	ប្រធានមន្ទីរ	ជាសមាជិកអចិន្ត្រៃយ៍
៤_លោក **ទិវា ជាង**	ប្រធានក្រុមហ៊ុនសៀង	ជាសមាជិក
៥_លោក **គីម ឃឿន**	ប្រធាននាយកដ្ឋានគណនេយ្យ	ជាសមាជិក
៦_លោក **លឹម សំអាត**	ប្រធានក្រុមហ៊ុនកាំប៉ិចស៊ីម	ជាសមាជិក

៧_លោក **ម៉ៅ ថូរ៉ា** ប្រធាននា. ព. ណក្រៅប្រទេស ជា សមាជិក

៨_លោក **ឆេង សារឿន** ប្រធានទីចាត់ការកាំកុងត្រូល ជាសមាជិក

៩_លោក **សុខ សារផល** ប្រធានក្រុមហ៊ុនកាំត្រង់ ជាសមាជិក

១០_លោក **យី គីមសេង** អនុប្រធាននាយកដ្ឋានផែនការ ជាសមាជិក

១១_លោក **កែ ផៃ** អនុប្រធានក្រុមហ៊ុនប្រមូលទិញ ជាសមាជិក

១២_លោក **ឆេស អែតដា** អនុប្រធានក្រុមហ៊ុនសំភារៈបរិក្ខារជាសមាជិក

១៣_លោក **ស៊ុំ សារ៉ាញ់** អនុប្រធានគណៈកម្មាធិការត្រួតពិនិត្យ ជាសមាជិក

១៤_លោក **សួស វណ្ណា** អនុប្រធាននាយកដ្ឋានបុគ្គលិក ជា សមាជិក

១៥_លោក **ឈួន ដារ៉ា** អនុប្រធានក្រុមហ៊ុនស្ថាបនា ជា សមាជិក

ប្រការ ២ : ចាត់តាំងអនុគណៈកម្មការចំនួន ៣ ដើម្បីជំនួយការដល់គណៈកម្មការពិពរ័ណ៍ជាតិ រួមមានសមាសភាពដូចខាងក្រោម ÷

I- អនុគណៈកម្មការរៀបចំតុបតែង :

១_លោក **អ៊ុំ សំផន**អនុប្រធានមន្ទីរ ជា ប្រធាន

២_លោក **ឈួន ដារ៉ា** អនុប្រធានក្រុមហ៊ុនស្ថាបនា ជាអនុប្រធាន

៣_លោក **សរ សំណាង** ប្រធានការិ. ត/ន កាំប៉ិចស៊ីម ជា សមាជិក

៤_លោក **ទ៉ាន់ គេង** ប្រធានការិ. ផ/ក ស្ថាបនា ជា សមាជិក

៥_លោក **វង្ស ចាន់តារា** អនុប្រធានការិ. រដ្ឋបាល មន្ទីរ ជា សមាជិក

៦_លោក **ម៉ិច ឆ៊ាន់** អនុប្រធានការិ. ផ្គត់ផ្គង់ មន្ទីរ ជា សមាជិក

អនុគណៈកម្មការនេះមានភារកិច្ចរៀបចំតុបតែងស្តង់សំរាប់តាំងទំនិញ

II- អនុគណៈកម្មការហិរញ្ញវត្ថុ :

១_លោក **ខ៊ិត សុគីន** អនុប្រធាននាយកដ្ឋានគណនេយ្យ ជាប្រធាន

២_អ្នកស្រី **ឡៅ្យ៉ង សារ៉ាត** អនុប្រធានមន្ទីរ ជាអនុប្រធាន

៣_លោក គោះ យាន អនុប្រធាននាយកដ្ឋានផែនការ ជាសមាជិក

៤_លោក សេង សំណាង ប្រធានការិ. ផ្គត់ផ្គង់ មន្ទីរ ជាសមាជិក

៥_អ្នកស្រី សំ ចាន់ នាយកដ្ឋានគណនេយ្យ ជាសមាជិក

៦_លោក ហ៊ិន សេងទន នាយកដ្ឋានគណនេយ្យ ជាសមាជិក

អនុគណៈកម្មការនេះ មានភារកិច្ចគិតគូរចំណូលចំណាយក្នុងការងាររៀបចំពិពរណ៍ជាតិរបស់ក្រសួង ។

III- អនុគណៈកម្មការផ្សព្វផ្សាយទំនាក់ទំនងសាធារណៈ :

១_លោក ម៉ៅ ថូរ៉ា ប្រធាននាយកដ្ឋានព. ណ. ក. បទ. ជាប្រធាន

២_លោក គីម សាន អនុប្រធាននាយកដ្ឋានព. ណ. ក. បទ ជាអនុប្រធាន

៣_លោក សម សម្បត្តិ អនុប្រធានក្រុមហ៊ុនកាំប៊ុចស៊ីម ជាសមាជិក

៤_លោក ទ្រៀក សារ៉ាន អនុប្រធានការិ. ផ្គត់ផ្គង់ មន្ទីរ ជាសមាជិក

៥_លោក ពូន ម៉ារ៉ែត អនុប្រធានការិ. ទំនាក់ទំនងសាធារណៈ ជាសមាជិក

អនុគណៈកម្មការនេះ មានភារកិច្ចទំនាក់ទំនងជាមួយបណ្ដាក្រុមហ៊ុនរកប្រភព ទំនិញសំរាប់តាំងពិពរណ៍ ។

ប្រការ ៣ : សមាជិកគណៈកម្មការ និងអនុគណៈកម្មការត្រូវចូលរួមប្រជុំពិភាក្សាតាមការអញ្ជើញរបស់ប្រធាន ។

ប្រការ ៤ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋាន និង ឯកឧត្តម អស់លោកដែលមានឈ្មោះខាងលើ ត្រូវទទួលអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

លី ឡាយស្រេង

* * *

៣ - ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ០៤ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៧៥៤ ឧម.ប្រក.

ស្ដីពីការបង្កើតការិយាល័យបរិដ្ឋានឧស្សាហកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទ[illegible]ព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ១១_១៩៩៣ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- ពិនិត្យសំណូមពរការងារចាំបាច់របស់ក្រសួង ។

សម្រេច

ប្រការ ១ : បង្កើតការិយាល័យបរិដ្ឋានឧស្សាហកម្ម ស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋាន បច្ចេកទេស ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ២ : ការិយាល័យបរិដ្ឋានឧស្សាហកម្ម មានភារកិច្ចគ្រប់គ្រង និងត្រួតពិនិត្យរាល់ការងារបរិដ្ឋាន ក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងនោះ មាន ÷

- ត្រួតពិនិត្យ និង ណែនាំការកែលំអរាល់ផលប៉ះពាល់ដល់បរិដ្ឋាន ដែលចេញ ពីការដ្ឋាន និង មូលដ្ឋានផលិតកម្មនានា
- ពិនិត្យវាយតំលៃហេតុប៉ះពាល់បរិដ្ឋានរបស់បណ្ដាគំរោង
- រៀបចំចងក្រងបទបញ្ញត្តិ ស្តង់ដារ និងកំរិតវង្វាស់ នៃការប៉ះពាល់ដល់បរិដ្ឋាន

– សិក្សាស្រាវជ្រាវអំពីមធ្យោបាយកាត់បន្ថយការប៉ះពាល់ដល់បរិស្ថាន និង ជំរុញការប្រើ ប្រាស់បច្ចេកវិទ្យា ដែលគ្មានការប៉ះពាល់ដល់បរិស្ថាន ។

ប្រការ ៣ : ការិយាល័យនេះត្រូវគ្រប់គ្រងដោយ ÷

– ប្រធានការិយាល័យមួយរូប

– អនុប្រធានការិយាល័យមួយចំនួន ។

ប្រការ ៤ : នាយកខុទ្ទកាល័យ ប្រធានមន្ទីរ គ្រប់ប្រធាននាយកដ្ឋាន ប្រធានគណៈកម្មាធិការត្រួតពិនិត្យមានភារកិច្ចអនុវត្តនូវប្រកាសនេះតាមមុខការរៀងៗខ្លួន។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ពូ សុធីរៈ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៧៦៣ ឧក. ប្រក

ប្រការ ១ : អនុញ្ញាតអោយលោក **ខា ផល្លា** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣១៦៦៣១ ក.ណ ចុះថ្ងៃទី ១៣-១២-៩០ អាស័យដ្ឋានបច្ចុប្បន្នភូមិ ក្នុង ឃុំ ព្រែកតាមាក់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ២៤ សេះ នៅក្នុងទីតាំង ភូមិពុកឫស្សីលើ ឃុំពុកឫស្សី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។

ប្រការ ២ : លោក **ខា ផល្លា** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម-សិប្បកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតម្លៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុង

ករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាស លេខ ៧៦៤ ឧក. ប្រក

ប្រការ ១ : អនុញ្ញាតអោយលោក **គី សុខុម** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៨៧៥៩៦ក.ព ចុះថ្ងៃទី ១៧-០២-៩២ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៦២ ផ្លូវលេខ ១៧៤ ក្រុម ៣៧ សង្កាត់ផ្សារថ្មី៣ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៤០ សេះនៅក្នុងទីតាំងភូមិ តាឡីក សង្កាត់ដង្កោ ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ ។

ប្រការ ២ : លោក **គី សុខុម** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតម្លៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៧៦៥ ឧក. ប្រក

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ឡូយ ឌុន** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៦០៧១៩ ភ.ព ចុះថ្ងៃទី ២៩-៨-៨៩ អាស័យដ្ឋានបច្ចុប្បន្ន ក្រុម ៦៩ សង្កាត់បឹងកក់ទី២ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១៦ សេះ នៅក្នុងទីតាំង ភូមិស្វាយអាត់លើ ឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។

ប្រការ ២ : អ្នកស្រី **ឡូយ ឌុន** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្គលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតម្លៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៧៦៦ ឧក.ប្រក

ប្រការ ១ : អនុញ្ញាតអោយលោក **ឡុច ខ្លា** ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ០៣៧២៧០ ភ.ព ចុះថ្ងៃទី ១៥-០១-៨៥ អាស័យដ្ឋានបច្ចុប្បន្នភូមិស្អាងថ្ម ឃុំស្អាងថ្ម ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១៨ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ឡុច ខ្លា** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្គលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតម្លៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៧៦៧ ឧក.ប្រក

ប្រការ ១ : អនុញ្ញាតអោយលោក **ទេខ លាងអេខ** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ១០១៥០៦ ក.ណ ចុះថ្ងៃទី ២២-៨-៨៧ អាស័យដ្ឋានបច្ចុប្បន្ន ភូមិទ្រាំងលើ ឃុំតាឯក ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១៥ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ទេខ លាងអេខ** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតម្លៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៧៦៨ ឧក.ប្រក

ប្រការ ១ : អនុញ្ញាតអោយលោក **ញឹម សាទី** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ១២០០៣០ ភ.ព ចុះថ្ងៃទី ០៩-៥-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១០៤ ភូមិ ក-៥ សង្កាត់អូរបែកក្អម ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៤០ សេះ នៅក្នុងទីតាំងភូមិកប់ក្អក សង្កាត់ភ្លើងឆេះរទេះ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

ប្រការ ២ : លោក **ញឹម សាទី** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដែល បានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្កលេខ ១ អោយបានយ៉ាងតិច បំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតម្លៃក្នុងរយពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៧៦៩ ឧក.ប្រក

ប្រការ ១ : អនុញ្ញាតអោយលោក **ស្រេង ម៉េងទ្រី** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១១០០២៧ ក.ណ ចុះថ្ងៃទី ១២-១០-៨៧ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ២៤២ ភូមិ អញ្ចែងក្រោម ឃុំពុកឫស្សី ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង៤០ សេះ នៅក្នុងទីតាំង ភូមិរលាជ្រូក សង្កាត់ព្រៃវែង ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

ប្រការ ២ : លោក **ស្រេង ម៉េងទ្រី** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្កលេខ ១ អោយបានយ៉ាងតិច បំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតម្លៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាលដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៧៧០ ផក.ប្រក

ប្រការ ១ : អនុញ្ញាតអោយលោក **ចុង ខាច** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២០៨៧៨៤ ស.រ ចុះថ្ងៃទី ១៤-១១-៩១ អាស័យដ្ឋានបច្ចុប្បន្ន ភូមិគោកថ្មី ឃុំពួក ខេត្តសៀមរាប ប្តូរទីតាំងរោងម៉ាស៊ីនផលិតទឹកកកដើម ពីទីតាំងចាស់ស្ថិតនៅផ្លូវជាតិលេខ៦ ភូមិគោកដូន ឃុំពួក ស្រុកពួក ខេត្តសៀមរាប ទៅទីតាំងថ្មីស្ថិតនៅ ភូមិពេជ្រោ ឃុំក្រឡាញ់ ស្រុកក្រឡាញ់ ខេត្តសៀមរាប ។

ប្រការ ២ : ប្រកាសនេះមានតម្លៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រឬបង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ ៣ : ប្រកាសលេខ ១៤៦ ផក.ប្រក ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ត្រូវចាត់ទុកជានិរាករណ៍ ។

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៧៧៥ ផក. ប្រក

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុនសុរាគារក្បាលពោធិ « **ម៉ៃ ឆេងអ៊ា** » ដែលមាន លោក **ហុង ស្រ៊ុន** ជាប្រធាន ពង្រីកផលិតកម្ម ដោយផលិតបន្ថែមនូវមុខផលិតផល ចំនួន ២ មុខទៀត គឺ អាល់កុល និង កែច្នៃស្រាជបសញ្ញា «គោពីរអោបផែនដីលើផ្ទៃចាំស៊ីហ្វិក» ស្របតាមគំរូសញ្ញាសំគាល់ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ២ : រាល់ប្រការដែលមានចែងក្នុងប្រកាសលេខ ៦៦៨ ផក. ប្រក ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៥ នៅមានតម្លៃជាធរមានបញ្ញត្តិដដែល ។

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៧៧៩ ផក. ប្រក

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន «សុរាគារកំពង់ត្រាំ » ដែលមានលោក **ខួន ថាវញ់** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៥០០៧៦ ភ. ព ចុះថ្ងៃទី ២២-៣-៨៩ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ២៨១ ផ្លូវលេខ ១៦៣ ក្រុមទី ១១ សង្កាត់ទួលទំពូង២ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរការផលិតកម្មនៅក្នុងទីតាំងភូមិ កំណប់ ឃុំរលាំងគ្រើល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។

ប្រការ ២ : លោក **ខួន ថាវញ់** ត្រូវបានអនុញ្ញាតផលិតនូវមុខផលិតផលស្រាអាកុលសញ្ញាសំគាល់ «រូបប្រាសាទព្រះវិហារ » ស្របតាមគំរូសញ្ញាសំគាល់ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតម្លៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រ

ជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះ នឹងត្រូវដក ហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ពូ សុធីរៈ

* * *

៤ - ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ២៤៨/៩៥ ពម.ប្រក

ស្តីពីការអនុញ្ញាតអោយកាសែត

«សង្គ្រោះខ្មែរ» ផ្លាស់ប្តូរការផ្សាយ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូកអវសានបញ្ញត្តិ មាត្រាទី ១៣៩ ។
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រ[illegible]ាក្សត្រនៃព្រ[illegible]ាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញព្រះរាជក្រមលេខ នស.រកម.០៨៩៥.០៧ ចុះថ្ងៃទី ០១ កញ្ញា ឆ្នាំ ១៩៩៥ ប្រកាសអោយប្រើច្បាប់ ស្តីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញប្រកាសរបស់ក្រសួងពត៌មានលេខ ០៩២_៩៥ ពម.ប្រក. ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៩៥ ស្តីពីការអនុញ្ញាតអោយដំណើរការ បោះពុម្ពផ្សាយសារពត៌មាន " សង្គ្រោះខ្មែរ " ។

- បានឃើញលិខិតរបស់លោក ឌ៉េត សន ចុះថ្ងៃទី ៧ កញ្ញា ១៩៩៥ ស្នើសុំផ្ទេរ ចាងហ្វាងការផ្សាយពីឈ្មោះ ឌ៉េត សន មកជា ថាន់ ឧត្ដរ វិញ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយកាសែត "សង្គ្រោះខ្មែរ" ផ្ទេរចាងហ្វាងការផ្សាយពីឈ្មោះ **ឌ៉េត សន** ជូន ទៅឈ្មោះ **ថាន់ ឧត្ដរ** វិញ ។

ប្រការ ២ : ខ្លឹមសារ អត្ថបទ និង សកម្មភាពផ្សព្វផ្សាយ ត្រូវអនុវត្តតាមប្រការ ២ នៃ សេចក្ដីប្រកាសរបស់ក្រសួងពត៌មាន ដូចចែងខាងលើនេះ រួចស្នើប្រគល់ កាសែតចំនួន ៦ច្បាប់ រៀងរាល់លេខ ចេញផ្សាយមកតំកល់ទុកជាឯកសារ នៅក្រសួងពត៌មាន ។

ប្រការ ៣ : លោក **ថាន់ ឧត្ដរ** ចាងហ្វាងការផ្សាយកាសែត " សង្គ្រោះខ្មែរ " និង នាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន ត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការ ៤ : ប្រកាសនេះ ចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
អៀង មូលី

* * *

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ២៤៩/៩៥ ពម.ប្រក.

ស្ដីពីការអនុញ្ញាតអោយកាសែត

THE BUSINESS NEWS

ចេញផ្សាយជាភាសាអង់គ្លេស

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់សារពត៌មាន ត្រូវបានរដ្ឋសភានៃរដ្ឋកម្ពុជា អនុម័ត នាសម័យប្រជុំវិសា មញ្ញ ថ្ងៃ ៥-៦ មេសា ១៩៩២ នីតិកាលទី ១ ។

- បានឃើញលិខិតសុំបើកការិយាល័យកាសែត THE BUSINESS NEWS ចុះថ្ងៃទី ១៧_ ៧_១៩៩៥ ។

សម្រេច

ប្រការ ១ : អនុញ្ញាតអោយកាសែត THE BUSINESS NEWS ចេញផ្សាយជាភាសាអង់គ្លេស ដែលមានលោក BALA CHANDRAN ជនជាតិម៉ាឡេស៊ី ជាប្រធានការិយាល័យ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ២ : ខ្លឹមសារ អត្ថបទ និង សកម្មភាពផ្សព្វផ្សាយត្រូវសមស្របតាមទំនៀមទំលាប់ ប្រពៃណី ល្អ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : គោរពច្បាប់សារពត៌មានតាមគោលការណ៍ តាមក្រមសីលធម៌ អ្នកកាសែត និង ឈរ លើស្មារតីទទួលខុសត្រូវខ្ពស់លើវិជ្ជាជីវៈរបស់ខ្លួន ។

ប្រការ ៤ : លោកប្រធានការិយាល័យកាសែត THE BUSINESS NEWS និង នាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន ត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះ ចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ២៥០/៣ម.ប្រក

ស្តីពីការអនុញ្ញាតអោយសារពត៌មាន

« នគរភ្លើ » ជំនេឋិការបោះពុម្ពផ្សាយ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូកអវសានបញ្ញត្តិ មាត្រាទី ១៣៩ ។

- បានឃើញព្រះរាជក្រឹត្យ របស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ន.ស.រ/ក.ម. ០៨៩៥/០៧ ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៥ ប្រកាសអោយប្រើច្បាប់ ស្តីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញពាក្យស្នើសុំបើកកាសែត " **នគរវត្ត** " របស់លោក **សុខ គីមសុវត្ថិ** ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ១៩៩៥ ។

សម្រេច

ប្រការ ១ : អនុញ្ញាតអោយសារពត៌មានឈ្មោះ «នគរវត្ត» ដំណើរការបោះពុម្ពផ្សាយ ដោយមានរូប លោក **សុខ គីមសុវត្ថិ** ជាចាងហ្វាងការផ្សាយ ។

ប្រការ ២ : ខ្លឹមសារអត្ថបទ និងសកម្មភាពផ្សព្វផ្សាយ ត្រូវសមស្របតាមទំនៀមទំលាប់ ប្រពៃណីល្អ និង ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : គោរពតាមគោលការណ៍ក្រមសីលធម៌អ្នកកាសែត និងឈរលើស្មារតីទទួល ខុសត្រូវខ្ពស់ លើវិជ្ជាជីវៈរបស់ខ្លួន និងប្រគល់កាសែតចំនួន ០៦ ច្បាប់ រៀងរាល់លេខចេញផ្សាយ មកតំកល់ទុកជាឯកសារ នៅក្រសួងពត៌មាន ។

ប្រការ ៤ : លោក **សុខ គីមសុវត្ថិ** ចាងហ្វាងការផ្សាយកាសែត " **នគរវត្ត** " និង នាយកដ្ឋានមណ្ឌលពត៌មាននៃក្រសួងពត៌មាន ត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

[illegible]

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ២៥១/៩៥ ពម.ប្រក

ស្តីពីការអនុញ្ញាតអោយកាសែត «យុត្តិធម៌»
បោះពុម្ពផ្សាយសាជាថ្មីឡើងវិញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូកអវសានបញ្ញត្តិ មាត្រាទី ១៣៩ ។
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ន.ស.រ.ក.ម. ០៨៩៥-០៧ ចុះថ្ងៃទី ០១ កញ្ញា ១៩៩៥ ប្រ កាសអោយប្រើច្បាប់ ស្តីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញប្រកាសបិទកាសែតយុត្តិធម៌លេខ ១៥៤-៩៤ ព.ម.ប្រ.ក. ចុះថ្ងៃទី៣០ ខែ ធ្នូ ឆ្នាំ ១៩៩៤ ។
- បានឃើញសំណើសុំបើកកាសែតយុត្តិធម៌សាជាថ្មីឡើងវិញរបស់លោក **ទេព សារឿន** ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ។

សម្រេច

ប្រការ ១ : អនុញ្ញាតអោយបោះពុម្ពផ្សាយកាសែត « **យុត្តិធម៌** » សាជាថ្មីឡើងវិញ ដែលមានលោក **ទេព សារឿន** ជាចាងហ្វាងកាផ្សាយ ។

ប្រការ ២ : ខ្លឹមសារអត្ថបទនិងសកម្មភាពផ្សព្វផ្សាយ ត្រូវសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : គោរពតាមគោលការណ៍ក្រមសីលធម៌អ្នកកាសែត និងឈរលើស្មារតីទទួលខុសត្រូវខ្ពស់លើ វិជ្ជាជីវៈរបស់ខ្លួន ព្រមទាំងស្នើប្រគល់កាសែតចំនួន ០៦

ប្រាប់ រៀងរាល់លេខចេញផ្សាយ ដើម្បី តំកល់ទុកជាឯកសារនៅ ក្រសួងព័ត៌មាន ។

ប្រការ ៤ : លោក **ខេង សារ៉ឿន** ជាចាងហ្វាងកាផ្សាយ និងនាយកដ្ឋានមណ្ឌលព័ត៌មាននៃក្រសួងព័ត៌មាន ត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ខៀវ កាញារីទ្ធ

* * *

៥ - ទីស្តីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ២ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ១៥៤ បទ.ប្រក

ស្តីពីការលុបឈ្មោះមន្ត្រី បុគ្គលិក រាជការ

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា ។

- បានឃើញសេចក្ដីសំរេចលេខ ១៨៤ សសរ ចុះថ្ងៃទី ២៥- ១២ - ៩០ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្ដីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពពលកម្មចំពោះកម្មាភិបាល បុគ្គលិក កម្មកររដ្ឋ
- បានឃើញច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល លេខ ០៦នស-៩៤ ចុះថ្ងៃទី៣០- ១០- ១៩៩៤ ។

សំរេច

ប្រការ ១ : លុបឈ្មោះមន្ត្រី បុគ្គលិករាជការចូលនិវត្តន៍ចំនួន ០៨ នាក់ ដូចមានរាយនាមខាងក្រោមចេញពីបញ្ជីក្របខ័ណ្ឌក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ចាប់ពីថ្ងៃទី ០១- ១០- ១៩៩៥

១-លោក **ងី សេងហៀង**	៥-លោក **តែ ឆាង**
២-លោក **លន ឡើយ**	៦-លោក **សុក សារិន**
៣-លោក **ឈី ម៉ិល**	៧-លោក **ឈឹម ឃន**
៤-លោក **ស្រ៊ុន ហួឈី**	៨-លោក **ឃិន ម៉េងជួន**

ប្រការ ២ : ខុទ្ទកាល័យ , អធិការដ្ឋាន , នាយកដ្ឋានផែនការគណនេយ្យ-ហិរញ្ញកិច្ច , នាយកដ្ឋានទូរ គមនាគមន៍ក្នុងប្រទេស និងសាមីខ្លួនទាំង ០៨ រូប ត្រូវទទួលបន្ទុក អនុវត្តតាមខ្លឹមសារនៃ ប្រកាសនេះ ។

ប្រការ ៣ : ប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

សូ ឃុន

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាស

លេខ : ១៥៥ បទ.ប្រក

ស្តីពីការតែងតាំងបជិក្ខាហកៈមន្ទីរ ប្រៃសណីយ៍ និង ទូរគមនាគមន៍

* * *

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ និងប្រកាសអោយប្រើនៅថ្ងៃទី ២០ កក្កដា ១៩៩៤
- បានឃើញប្រកាសលេខ ០៨២ ប្រក.បទ ចុះថ្ងៃទី ២៩ កក្កដា ១៩៩៤ ស្តីពីការរៀបចំ រចនាសម្ព័ន្ធមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខ្សែរយៈបណ្តោយ គ្រប់ខេត្ត-ក្រុង
- យោងតាមស្មារតីអង្គប្រជុំថ្នាក់ដឹកនាំ នាថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៥

សម្រេច

ប្រការ ១ : តែងតាំងមន្ត្រីរាជការចំនួនចំនួន ០២រូប ដូចមានឈ្មោះខាងក្រោម ជាបជិក្ខាហកៈរងនៃ មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ខេត្តស្ទឹងត្រែង :

១-លោក **ង៉ែ សុភទណ្ឌី** បជិក្ខាហកៈរង ទទួលបន្ទុករួម

២-លោក **ឌិត សារ៉េត** បជិក្ខាហកៈរង

ប្រការ ២ : បជិក្ខាហកៈរងមានភារកកិច្ចគ្រប់គ្រង ដឹកនាំ និងទទួលខុសត្រូវលើការងារសេវាកម្មអាជីវកម្ម ប្រៃសណីយ៍ និងទូរគមនាគមន៍ ទូទាំងខេត្ត-ស្រុកជួសមុខអោយក្រសួង ។

ប្រការ ៣ : នាយកខុទ្ទកាល័យ, អធិការដ្ឋាន, នាយកដ្ឋានផែនការគណនេយ្យ ហិរញ្ញវត្ថុ នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស , នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ នាយកដ្ឋានប្រៃសណីយ៍ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ។

ប្រការ ៤ : ប្រកាសលេខ ១៧៩ បទ.ប្រក ចុះថ្ងៃទី ៧ ខែ ១១ ឆ្នាំ ១៩៩៤ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : ប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

សូ យុន

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ១៥៦ បទ.ប្រក

ស្តីពីការបង្កើតក្រុមប្រឹក្សាវិន័យ

***

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការ ស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

សម្រេច

ប្រការ ១ : បង្កើតក្រុមប្រឹក្សាវិន័យ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដែលមានសមាស ភាពដូចតទៅ ÷

១-ឯកឧត្តម **ផាន់ តិន**	អនុរដ្ឋលេខាធិការ	ប្រធាន
២-លោក **គ្រី ឆេង**	អនុប្រធានអធិការដ្ឋាន	សមាជិក
៣-លោក **កែវ ចន្ធឿន**	អនុប្រធាននាយកដ្ឋានផែនការ ហិរញ្ញវត្ថុ	គណនេយ្យ សមាជិក
៤-លោក **ព្រាប សុរិទ្ធិ**	អនុប្រធាននាយកដ្ឋានប្រៃសណីយ៍	សមាជិក
៥-លោក **អ៊ុច សុខុម**	អនុប្រធានការិយាល័យបុគ្គលិក	ធ្វើរបាយការណ៍

ប្រការ ២ : ក្រុមប្រឹក្សាវិន័យរបស់ក្រសួងនេះ មានភារកិច្ចពិភាក្សា ពិនិត្យពិចារណា លើករណីទាំងឡាយដែលមន្ត្រីរាជការបានអនុវត្តខុសនឹងបទបញ្ជារបស់ក្រសួង ។

ប្រការ ៣ : មន្ត្រីដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ។

ប្រការ ៤ : រាល់ប្រកាសបង្កើតក្រុមប្រឹក្សាវិន័យណាដែលផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៥ : ប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា
សូ ឃុន

* * *

រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ១៥៧ បទ.ប្រក

ស្តីពីការតែងតាំងមន្ត្រីរាជការ

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា ។
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- យោងស្មារតីអង្គប្រជុំថ្នាក់ដឹកនាំនាថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៥

សម្រេច

ប្រការ ១ : តែងតាំងមន្ត្រី រាជការចំនួន ១១នាក់នៅនាយកដ្ឋានផែនការ គណនេយ្យ ហិរញ្ញវត្ថុ ,នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ ដែលមានរាយនាមដូចខាងក្រោមអោយទទួលតួនាទីភារកិច្ចដូចតទៅ ÷

I - នាយកដ្ឋានផែនការ -គណនេយ្យ-ហិរញ្ញកិច្ច :

១-លោក **ម៉ក់ មាន** ប្រធានការិយាល័យវិក័យប័ត្រ

២-លោក **ឥន្ទ វណ្ណៈ** អនុប្រធានការិយាល័យវិក័យប័ត្រអន្តរជាតិ

៣-អ្នកស្រី **អ៊ុំ គឿន** អនុប្រធានការិយាល័យជំពាក់ព័ន្ធ

៤-លោក **អ៊ុក សុគន** អនុប្រធានការិយាល័យផែនការ ស្ថិតិ

II - នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ :

១-លោក **ស៊ា ណារ៉េត** អនុប្រធាននាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ

៤-កញ្ញា **អួន អមរា** ប្រធានមជ្ឈមណ្ឌលមាត់ច្រកអន្តរជាតិ

៥-កញ្ញា **សំ សុវិជ្ជា** ប្រធានមជ្ឈមណ្ឌល I T M C

៦-លោក **អ៊ូ មាន** អនុប្រធានមជ្ឈមណ្ឌលភ្ជាប់រួម I.NTELSAT

៧-លោក **ម៉ុច ចរិយា** ប្រធានមជ្ឈមណ្ឌលកុំព្យូទ័រ

ប្រការ ២ : មន្ត្រីរាជការ ដូចចែងក្នុងប្រការ១ ត្រូវអនុវត្តតាមតួនាទីភារកិច្ច និងនៅក្នុងសមត្ថកិច្ចរបស់ខ្លួនដែលមានចែងក្នុងរចនាសម្ព័ន្ធរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដែលបានផ្ញើជូនរាជរដ្ឋាភិបាល តាមលិខិតលេខ ០៧៧ ប.ទ ចុះថ្ងៃទី ១១ សីហា ១៩៩៣ ។

ប្រការ ៣ : ខុទ្ទកាល័យ , អធិការដ្ឋាន , នាយកដ្ឋានផែនការគណនេយ្យ ហិរញ្ញកិច្ច , នាយក ដ្ឋានគមនាគមន៍អន្តរជាតិ និងសាមីខ្លួនទាំង ១១ រូប ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ។

ប្រការ ៤ : រាល់ប្រកាសដែលផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : ប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

សូ ឃុន

* * *

៦ - រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ១០២០ មស.មល

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល លេខ នស.រកត ១០៩៤ - ៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤
- បានឃើញការចាំបាច់របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

សំរេច

ប្រការ ១ : តែងតាំងលោក **ម៉េង ម៉ុនណា** អនុប្រធានការិយាល័យ-រដ្ឋបាល-បុគ្គលិក

- តែងតាំងលោក **តេង គឹមដារ៉ា** ជាអនុប្រធានការិយាល័យហិរញ្ញវត្ថុ ។

ប្រការ ២ : ខុទ្ទកាល័យ នាយកដ្ឋានក្របខ័ណ្ឌ នាយកដ្ឋាននីតិកម្ម នាយកដ្ឋានបៀវត្ស និងសាមីខ្លួនត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ប្រាក់ សុខ

* * *

៧ - ទីស្តីការក្រសួងធម្មការ និង សាសនា

ប្រកាស

ភ្នំពេញ , ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ២០១/៩៥ កធស.ប្រក

ស្តីពីការតែងតាំងមន្ត្រីរាជការ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ។
- បានឃើញច្បាប់ ស្តីពីការបង្កើតទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមក្រឹតលេខ ១៧ ក្រ ចុះថ្ងៃទី ៨ កុម្ភៈ ឆ្នាំ ១៩៩២
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ១៩៩២ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា
- បានឃើញលិខិតលេខ ១៩១.៩៥ មធស.កព ចុះថ្ងៃទី ១៣ ខែ កក្កដា ១៩៩៥ របស់ មន្ទីរធម្មការ និងសាសនា ខេត្តកំពត
- បានឃើញលិខិតលេខ ១១២ លខស.កព ៩៥ ចុះថ្ងៃទី ១៣ ខែ កក្កដា ១៩៩៥ របស់សាលាខេត្តកំពត ។

សម្រេច

ប្រការ ១ : តែងតាំងលោក **ឡី ហេង** បច្ចុប្បន្នជាអនុប្រធានការិយាល័យធម្មការ និងសាសនា ស្រុកឈូក ជាប្រធានការិយាល័យធម្មការ និងសាសនា ស្រុកឈូក ។

-លោក **ម៉េង ម៉ន** បច្ចុប្បន្នអនុប្រធានការិយាល័យធម្មការ និងសាស ស្រុក កំពត ជាប្រធានការិយាល័យធម្មការ និង សាសនា ស្រុកកំពត ។

ប្រការ ២ : មន្ទីរធម្មការនិងសាសនាខេត្ត មន្ទីរហិរញ្ញវត្ថុខេត្ត មន្ទីរផែនការកំពត និង អស់លោក ដែលមានចែងក្នុងប្រការ១ ត្រូវអនុវត្តរៀង ។ ខ្លួន តាមសេចក្តីប្រកាសនេះ ។

ប្រការ ៣ : សេចក្តីប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

ហត្ថលេខានិងត្រា

ហៀង.ចណ្ណារ័ត្ន

៨ - ទីស្តីការរដ្ឋមន្ត្រីក្រសួងគ្រប់គ្រងបរិដ្ឋាន

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ១៨២២ .ប្រក.បស្ថ

ស្តីពីការទទួលស្គាល់និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

ផ្ទេរមកបំរើការងារនៅក្រសួងគ្រប់គ្រងបរិដ្ឋាន

===

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។
- បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ១៩៩៤ ដែលប្រកាសដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងប្រកាសលេខ ៥៧៥ ប្រក.កសក.ចត ចុះថ្ងៃទី ១១-៩-៩៥ របស់ក្រសួងកសិកម្មរុក្ខា ប្រមាញ់ និងនេសាទ ។
- ផ្អែកតាមតម្រូវការចាំបាច់ របស់ក្រសួងគ្រប់គ្រងបរិដ្ឋាន ។

សម្រេច

ប្រការ ១ : ទទួលស្គាល់ និងប្រគល់ភារកិច្ចជូនលោក **គង់ សៀកលី** អោយបំរើការងារនៅមន្ទីរគ្រប់ គ្រងបរិដ្ឋានរាជធានីភ្នំពេញ ។

ប្រការ ២ : ប្រាក់បៀវត្ស និងរបបឧបត្ថម្ភផ្សេង ៗ ក្រសួងគ្រប់គ្រងបរិដ្ឋានជានាគ្រប់គ្រងបន្តនៅពេល មានវិញ្ញាបនប័ត្រផ្តាច់ប្រាក់ពីអង្គភាពដើម ។

ប្រការ ៣ : អគ្គនាយក ខុទ្ទកាល័យ អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនទទួលបន្ទុកអនុវត្តន៍ប្រការនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

បណ្ឌិត **ម៉ុក ម៉ារ៉េត**

* * *

៩ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១១៦ ប្រក.វវស.ប.

ស្តីពីការផ្លាស់ប្តូរកន្លែងធ្វើការរបស់មន្ត្រីរាជការ មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈរាជធានីភ្នំពេញ

* * *

រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមលិខិតលេខ ២០៦៨ ឈ.ស ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ១៩៩៥ ស្តីពីការ ស្នើសុំផ្ទេរលោក គង់ សារាជ មន្ត្រីមន្ទីរវប្បធម៌ និង

វិចិត្រសិល្បៈរាជធានីភ្នំពេញមក បំរើការងារនៅសាលាក្រុងភ្នំពេញរបស់ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ

- យោងលិខិតលេខ ១៣៥ លខវវស.បុចុះថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ១៩៩៥ របស់ក្រសួង វប្បធម៌ និង វិចិត្រសិល្បៈ
- យោងលិខិតលេខ ២៣៨ សករណរប ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ១៩៩៥ របស់ ក្រសួងមហាផ្ទៃ

សំរេច

ប្រការ ១ : លោក **គង់ សារាជ** មន្ត្រីមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈរាជធានីភ្នំពេញត្រូវបានអនុញ្ញាតអោយ ផ្លាស់ទៅបំរើការងារនៅសាលាក្រុងភ្នំពេញ ។

ប្រការ ២ : មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈរាជធានីភ្នំពេញត្រូវផ្ទេរប្រាក់បៀវត្សរបបឧបត្ថម្ភផ្សេង ៗ របស់សាមីខ្លួន និងក្របខ័ណ្ឌមួយកន្លែងជូនសាលាក្រុងភ្នំពេញ ។

ប្រការ ៣ : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈរាជធានីភ្នំពេញ និង លោក **គង់ សារាជ** មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ស៊ីសុវត្ថិ សិរីវុឌ ប៉ាណារ៉ា

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៦៧ ប្រក.វវស.ប,
ស្តីពីការលុបឈ្មោះមន្ត្រីរាជការ
មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្តកំពត

* * *

រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើលុបឈ្មោះលេខ ២៤៣ ចករវ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៩៥ របស់មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តកំពត
- យោងតាមចំណារយល់ព្រមពីថ្នាក់ដឹកនាំក្រសួងចុះថ្ងៃទី ២ ខែ តុលា ឆ្នាំ ១៩៩៥

សម្រេច

ប្រការ ១ : អ្នកស្រី **សម ចរិយា** បុគ្គលិកការិយាល័យរដ្ឋបាល នៃមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្ត កំពតត្រូវបានអនុញ្ញាតអោយលុបឈ្មោះចេញពីបញ្ជី ក្របខ័ណ្ឌមន្ត្រីរាជការ មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្តកំពតចាប់ ពីថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ដោយសុំលាឈប់ ពីការងារ និងបាន ទទួលរបបឧបត្ថម្ភគោលនយោបាយតាមការកំណត់របស់រាជរដ្ឋាភិបាល កម្ពុជា ។

ប្រការ ២ : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្ត កំពត និង អ្នក ស្រី **សម ចរិយា** មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

បាត្រលោកា និង ត្រា

ស៊ីសុវត្ថិ សិរីវុធ ម៉ាណារ៉ា

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៦៨ ប្រក.វបស.ប្ក

ស្តីពីការផ្លាស់ប្តូរកន្លែងធ្វើការ

រដ្ឋមន្ត្រី និង ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច**នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រនៃព្រះរា ណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែ ជរដ្ឋាភិបាលកម្ពុជា
- យោងលិខិតលេខ ២៥២៣ អយក.ចត ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ របស់ ក្រសួងអប់រំយុវជន និង កីឡា

សម្រេច

ប្រការ ១ : កញ្ញា **ម៉ុន សុផានី** គ្រូមធ្យមសិក្សាកំរិត២ នៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈត្រូវ បានអនុញ្ញាតអោយផ្លាស់ទៅបំរើការងារនៅក្រសួងអប់រំយុវជន និងកីឡា ។

ប្រការ ២ : ក្រសួងនឹងផ្ទេរប្រាក់បៀវត្ស និង របបឧបត្ថម្ភផ្សេង ៗ របស់កញ្ញា **ម៉ុន សុផានី** និងក្រប ខ័ណ្ឌមួយកន្លែងជូនក្រសួងអប់រំយុវជននិងកីឡា ។

ប្រការ ៣ : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានបច្ចេកទេស សាកលវិទ្យាល័យភូមិន្ទ វិចិត្រសិល្បៈ និង កញ្ញា **ម៉ុន សុផានី** មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ស៊ីសុវត្ថិ សិរីវុធ ប៉ាណារ៉ា

* * *

បោះពុម្ពនៅរោងពុម្ពទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ១២៨៨ រៀល